# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

AMK PLC CREDIT LENDING PROCESS

**ជំនាញ គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

# ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី
AMK PLC CREDIT LENDING PROCESS

**គ្រូណែនាំ៖ សួរ ចិត្ត្រា**

**ជំនាញ គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**

**ប្រធានបទ៖ ដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

**អេ អឹម ខេ ភីអិលស៊ី**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

សួរ ចិត្រា

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ គណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យគឺជាជំនាញមួយមានសារៈសំខាន់ដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយ ឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខ ជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារ គណនេយ្យនិងហិរញ្ញវត្ថុ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូត ដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារ ធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុ សាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបាន ល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ បានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**ដំណើរការនៃការផ្តល់ឥណទាន របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោល បំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និង ប្រសិទ្ធភាពនៃការផ្តល់ ឥណទានរបស់មីក្រូហិរញ្ញវត្ថុ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការ ស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពី កិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នក អានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំ រីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អ ប្រសើរ។

# រចនាសម្ព័ន្ធ



**សុខ សាមើ**
ID: B22/220



**ម៉ៅ មិថុនា**
ID: B22/219



**តា កញ្ញា**
ID: B22/205



**សុខ ស្រីលីស**
ID: B22/214



**រុំ ជាលីស**
ID: B22/298

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់យើងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថានវ៉ាន់ដាដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះគ្រូណែនាំ **សួរ ចិន្ត្រា** ជាគ្រូណែនាំដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "ដំណើការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី" នេះគឺជាស្នាដៃរបស់ក្រុមយើងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃសុក្រ ៣កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



សុខ សាមើ

# សេចក្ដីសង្ខេបនៃការស្រាវជ្រាវ

សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី ជាគ្រឹះស្ថានមីក្រូនៅក្នុងស្រុកមួយ ដែលមានការទទួលស្គាល់ និងទុកចិត្តអំពីសំណាក់សាធារណជន និងបានចូលរួមចំណែកដ៏ធំមួយនៅក្នុងការជួយជំរុញ និងការអភិវឌ្ឍលើវិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនទូទាំងពិភពលោកដែលជារៀងរាល់ពេលហើយ គ្រប់មធ្យោបាយទាំងអស់បានពាក់ព័ន្ធទៅនឹងទិដ្ឋភាពការផ្ដល់ឥណទានរបស់ពិភពលោកដូចជា អតិថិជនដែលជាអ្នកជំនួញ អាជីវកម្មតូច ធំ ជាច្រើនសុទ្ធតែប្រើប្រាស់ សេវាកម្មឥណទាន។ ហេតុដូចនេះហើយយើងទាំងអស់គ្នាត្រូវយល់ដឹងអំពីឥណទាន និងការប្រើប្រាស់ ច្បាប់ និងនិយ័តកម្មឥណទានយ៉ាងដូចម្ដេចដែរ។ ជាពិសេស នៅតាមទីជនបទដាច់ស្រយាលដែលមិនទាន់មានធនាគារធំៗ សម្រាប់ការផ្ដល់ឥណទាននោះទេ។ ហេតុដូចនេះហើយ ទើបគេបង្កើតឡើងនូវដំណើរការនៃការគ្រប់គ្រងការផ្ដល់ឥណទាននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ដែលមានគោលបំណង ច្បាស់លាស់ក្នុងគោលបំណងទាំងនោះទាមទារ ចាំបាច់នៃការផ្សារភ្ជាប់ទ្រឹស្ដី និងការអនុវត្តជាក់ស្ដែងដើម្បីឱ្យអ្វីដែលយើងបានសិក្សាកន្លងមកនោះក្លាយទៅជាដើមទុនយ៉ាងសំខាន់ នៅក្នុងការអនុវត្តការងារឱ្យមានប្រសិទ្ធភាពទៅថ្ងៃអនាគត នៅតាមក្រុមហ៊ុន ឬស្ថាប័ននានា។

ក្រោយពីបានសិក្សាស្រាវជ្រាវកន្លងមក ធ្វើឱ្យក្រុមយើងទទួលបានលទ្ធផលសំខាន់ៗជាច្រើនពី ដំណើរការនៃការគ្រប់គ្រងឥណទាន ដូចជាយល់ដឹងពីទស្សនៈវិស័យ បេសកម្ម រចនាសម្ព័ន្ធភាគទុនិក ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង ក៏ដូចជាតំបន់ប្រតិបត្តិការសំខាន់ៗរបស់ អេ អឹម ខេ មិនតែប៉ុណ្ណោះក៏ធ្វើឱ្យយើងយល់ដឹងបន្ថែមអំពីផលិតផល និងសេវាកម្មផ្សេងៗដែលមាននៅក្នុងគ្រឹះស្ថាន។ ម៉្យាងទៀត យល់ដឹងអំពីដំណើរការនៃការផ្ដល់ឥណទាន រចនាសម្ព័ន្ធឥណទាន នីតិវិធីនៃការផ្ដល់ឥណទាន និងគោលនយោបាយក្នុងការផ្ដល់កម្ចីបានយ៉ាងច្បាស់លាស់។

តាមរយៈការសិក្សាស្រាវជ្រាវទៅលើការផ្ដល់ឥណទានរបស់ អេ អឹម ខេ យើងខ្ញុំអាចសន្និដ្ឋានបានថា មានលក្ខណៈវិជ្ជមានច្រើនជាងចំណុចអវិជ្ជមានដែលហេតុធ្វើឱ្យគ្រឹះស្ថានមានការរីកចម្រើនជាលំដាប់ដល់សព្វថ្ងៃនេះ។ ថ្វីត្បិតតែការផ្ដល់ឥណទានមានចំណុចវិជ្ជមានច្រើនជាងចំណុចអវិជ្ជមានក៏ពិតមែន តែក៏មានបញ្ហាបន្តិចបន្តួចគួរតែដោះស្រាយដូចជាការកាត់បន្ថយអត្រាការប្រាក់ និង ការផ្សព្វផ្សាយរាល់ព័ត៌មានដែលទាក់ទងនិងសេវាកម្មផ្ដល់ឥណទានក៏ដូចជាពង្រឹងបន្ថែមនូវឧបករណ៍ អេឡិចត្រូនិច ដើម្បីជាអត្ថប្រយោជន៍ និងភាពងាយស្រួលក្នុងការទាក់ទាញអតិថិជនឱ្យអតិថិជនមកទទួលឥណទានមួយនេះ។

# មាតិកា

ទំព័រ

អារម្ភកថា ........................................................................................................ i
រចនាសម្ព័ន្ធ........................................................................................................ ii
សេចក្ដីថ្លែងអំណរគុណ ........................................................................................ iii
អំណះអំណាង........................................................................................................ iv
សេចក្ដីសង្ខេបនៃការស្រាវជ្រាវ ................................................................................ v
មាតិកា........................................................................................................ vi

## ជំពូកទី១
## សេចក្ដីផ្ដើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........................................................................ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ........................................................................ ១
　　១. តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី មានប្រភេទឥណទានអ្វី?
　　២. តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី មាននីតិវិធីនៃការផ្ដល់ឥណទានដូចម្ដេច?
១.៣ គោលបំណងនៃការស្រាវជ្រាវ........................................................................ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ................................................ ២
　　១.៤.១ ទំហំដែនកំណត់ ........................................................................ ២
　　១.៤.២ វិសាលភាពនៃការស្រាវជ្រាវ........................................................ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ........................................................................ ២
　　១.៥.១ ការប្រមូលទិន្នន័យដំបូង........................................................ ២
　　១.៥.២ ការប្រមូលទិន្នន័យបន្ទាប់បន្សំ ................................................ ២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ........................................................................ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........................................................................ ៣

## ជំពូកទី២
## ដំណើរការនៃការផ្ដល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

២.១ លក្ខណៈនៃការផ្ដល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ................................ ៥
　　២.១.១ និយមន័យឥណទាន ........................................................................ ៥
　　២.១.២ ប្រវត្តិឥណទាន ........................................................................ ៥
　　២.១.៣ ប្រភេទនៃឥណទានសំខាន់ៗ ................................................................ ៦
២.២ តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ........................................................................ ៨
　　២.២.១ និយមន័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ................................................ ៨
　　២.២.២ ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ................................................ ៨

២.២.៣ តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ....................................................................៩
២.៣ ដំណើរការនៃការសម្រេចផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ........................................១១
២.៣.១ និយមន័យហិរញ្ញវត្ថុ ................................................................................................. ១១
២.៣.២ ប្រវត្តិរបស់ហិរញ្ញវត្ថុ .................................................................................................១២
២.៣.៣ ច្បាប់ស្តីពីដើមទុនក្នុងការបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ..................................................១២

## ជំពូកទី៣

## ដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

៣.១ ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី ........................................ ១៤
៣.១.១ ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី ......................................... ១៤
៣.១.២ គោលនយោបាយរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី .......................១៧
ក.ចក្ខុវិស័យ ..........................................................................................................១៧
ខ.បេសកកម្ម...........................................................................................................១៧
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី ................................................................................................................... ១៨
ក. រចនាសម្ព័ន្ធគ្រប់គ្រង.......................................................................................... ១៨
ខ. តួនាទីគណៈគ្រប់គ្រង .........................................................................................២១
៣.២ ប្រភេទឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី...................................២៦
៣.២.១ ឥណទានជាក្រុម...................................................................................................២៦
៣.២.២ ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន .................................................................................. ២៧
៣.២.៣ ឥណទានខ្នាតតូចបំផុតនឹងតូច..................................................................................២៨
៣.២.៤ ឥណទានខ្នាតមធ្យម............................................................................................... ២៩
៣.២.៥. ផលិតផលភតិសន្យាហិរញ្ញវត្ថុឡាន ....................................................................... ២៩
៣.៣ នីតិវិធីក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី ....................... ៣០
ក.និតិវិធីក្នុងឥណទាន ............................................................................................. ៣០
ខ.ដំណើរការអនុម័តឥណទាន.................................................................................... ៣១
៣.៣.២ ប្រភេទនៃហានិភ័យ...............................................................................................៣១
៣.៣.៣ ការបង្ការហានិភ័យ ...............................................................................................៣២
៣.៣.៤ ការត្រួតពិនិត្យលើការបាត់បង់ ................................................................................ ៣៥
៣.៣.៥ ការបាត់បង់ហិរញ្ញវត្ថុ............................................................................................ ៣៥
៣.៣.៦ ការកាត់បន្ថយហានិភ័យផ្ទៃក្នុង................................................................................ ៣៦

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង................................................................................................ ៣៧
៤.២ ការវិភាគលើចំណុចខ្សោយ ................................................................................................ ៣៧

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ................................................................................................ ៣៨
៥.២ ការផ្តល់អនុសាសន៍ ................................................................................................ ៣៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

សព្វថ្ងៃនេះប្រទេសកម្ពុជា ជាប្រទេសមួយកំពុងអភិវឌ្ឍលើគ្រប់វិស័យ។ ក្រោយពីទទួលបានសន្តិភាពពេញលេញហើយ កម្ពុជាក៏បានស្តារហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ដោយមានការជួយជ្រោមជ្រែងពីសំណាក់សមាគមន៍អន្តរជាតិ និងបណ្តាប្រទេសនានាដែលជាដៃគូអភិវឌ្ឍន៍ ក្នុងនោះមានការបើកទូលាយខាងវិស័យពាណិជ្ជកម្ម វិស័យសេដ្ឋកិច្ចទីផ្សារ វិស័យធនាគារ ហើយធ្វើឱ្យវិស័យទាំងអស់នៅប្រទេសកម្ពុជាមានការរីកចម្រើនលូតលាស់ឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ។ បច្ចុប្បន្ន បើយើងក្រឡេកទៅមើលខាងវិស័យធនាគារ និងហិរញ្ញវត្ថុវិញយើងឃើញថា មានការរីកចម្រើនយ៉ាងខ្លាំង ព្រោះវិស័យនេះ បានជួយស្តារសេដ្ឋកិច្ចជាតិឱ្យកាន់តែមានភាពរីកចម្រើន និងការអភិវឌ្ឍដ៏មានប្រសិទ្ធភាព។ ក្រោមការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល និងគោលនយោបាយដ៏មានប្រសិទ្ធភាព បានធ្វើឱ្យប្រទេសកម្ពុជាទទួលបាននៅសុខសន្តិភាព និងស្ថេរភាពក្នុងសង្គម ព្រមទាំងបង្ហាញឱ្យឃើញនូវសក្តានុពលខាងផ្នែកសេដ្ឋកិច្ចជាច្រើននៅប្រទេសកម្ពុជា ដែលជាហេតុនាំឱ្យអ្នកវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុកមានចំណាប់អារម្មណ៍បានមកធ្វើការវិនិយោគជាច្រើន។ ដូច្នេះហើយ តម្រូវការផ្នែកហិរញ្ញវត្ថុ មានការកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា។

ទន្ទឹមនឹងការរីកចម្រើនយ៉ាងឆាប់រហ័សខាងផ្នែកហិរញ្ញវត្ថុនេះ ទើបបណ្តាលឱ្យកើតមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារជាច្រើនមកបំពេញតម្រូវការផ្នែកហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋ និងអ្នកវិនិយោគតាមរយៈការផ្តល់នូវសេវាកម្មដូចជា (១.ការផ្តល់ឥណទាន ២.ការទូទាត់ ៣.ការទទួលប្រាក់បញ្ញើ)។ ការដើរតួជាអ្នកផ្តល់ហរិញ្ញប្បទាន គឺពិតជាមានផលលំបាកណាស់ ព្រោះការផ្តល់ឥណទានមានហានិភ័យខ្ពស់ និងពិបាកគ្រប់គ្រងឥណទានទាំងកត្តាខាងក្នុង និងកត្តាខាងក្រៅ។

ដោយយល់ឃើញថាបច្ចុប្បន្ន ភាពរីកចម្រើននៃគ្រឹះស្ថានមីក្រូហរិញ្ញវត្ថុមានការរីកដុះដាលគួរឱ្យកត់សម្គាល់ ហេតុដូចនេះទើបក្រុមយើងខ្ញុំបានជ្រើសរើសយកប្រធានបទស្តីពី **"ដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហរិញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី"** យកមកស្រាវជ្រាវ និងស្វែងយល់បន្ថែមឱ្យកាន់តែច្បាស់លាស់ទាក់ទងនិងដំណើរការនៃការផ្តល់ឥណទាននេះ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

សព្វថ្ងៃ ថ្វីបើប្រទេសកម្ពុជាយើងមានការកើនឡើងជាលំដាប់លំដោយលើវិស័យមួយនេះក្តី ក៏ប្រទេសមួយនេះ នៅតែមានភាពលំបាកក្នុងការអភិវឌ្ឍន៍នៅឡើយ ពីព្រោះការកើនឡើងនៅចំនួនប្រជាជន ដែលមានជីវភាពក្រីក្រផងដែរ ហេតុនេះហើយ ទើបការផ្តល់ឥណទានក្លាយជាតម្រូវការយ៉ាងចាំបាច់សម្រាប់ជួយដល់ប្រជាជនឱ្យមានភាពល្អប្រសើរក្នុងជីវភាពប្រចាំថ្ងៃ និងដើម្បីបំពេញនៅសេចក្តីត្រូវការរបស់អតិថិជនក្នុងទីផ្សារ។ ម៉្យាងវិញទៀត ថ្នាក់ដឹកនាំគ្រប់ស្ថាប័ន ឬមន្ត្រីឥណទានទាំងឡាយ ត្រូវតែមានការបណ្តុះបណ្តាលបង្កើននៅសមត្ថភាពបុគ្គលិកលក្ខណៈ ជាពិសេស មានភាពពេញលេញក្នុងការផ្តល់សេវាកម្មឥណទានជូនចំពោះអតិថិជនគ្រប់ផ្នែក សាខាខេត្ត-ក្រុង គឺជាចំណុចចម្បងមួយដែលមាន សុវត្ថិភាព និងគណៈគ្រប់គ្រង

បានយកចិត្តទុកដាក់ខ្ពស់។ មូលហេតុនេះហើយ បានជាក្រុមយើងខ្ញុំលើកយកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី ដោយផ្តោតសំខាន់ទៅលើការផ្តល់ឥណទានមួយមុខមកបរិយាយតែប៉ុណ្ណោះ។

១. តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ីមានប្រភេទឥណទានអ្វីខ្លះ?

២. តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ីមាននីតិវិធីនៃការផ្តល់ឥណទានដូចម្តេច?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សានេះមានគោលបំណងដើម្បីងាយស្រួលដល់ការធ្វើគម្រោងនៃការស្រាវជ្រាវដូចខាងក្រោម៖

- ស្វែងយល់ពីស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី (AMKPLC)
- ការសិក្សាស្វែងយល់ពីគោលនយោបាយ ប្រភេទឥណទានរបស់គ្រឹះស្ថាន
- ការសិក្សាពីនីតិវិធី និងដំណើរការនៃផ្តល់ឥណទាន

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ការសិក្សានេះ គឺជាការសិក្សាស្រាវជ្រាវពីការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី អាសយដ្ឋាន៖ អគារលេខ២៨៥ មហាវិថីយោធពលខេមរភូមិន្ទ(២៧១) សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ប្រទេសកម្ពុជាដែលផ្តោតទៅលើគោលការណ៍នៃនីតិវិធីក្នុងការផ្តល់ឥណទាន ទំហំឥណទាន និងអត្រាការប្រាក់។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

តាមការជាក់ស្តែងដោយសារតែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី មានសាខាច្រើន និងទិន្នន័យច្រើន ដូច្នេះក្រុមយើងខ្ញុំក៏សូមលើកយកទិន្នន័យនៅក្នុងឆ្នាំ២០២៤ មកសិក្សាស្រាវជ្រាវ ដើម្បីធ្វើជារបាយការណ៍។

## ១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ

ការស្រាវជ្រាវបានប្រើប្រាស់តាមវិធីសាស្ត្រគុណវិស័យដោយផ្តោតចម្បងទៅលើការវិភាគទិន្នន័យនិងឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់អំពី "ដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី"។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្រ្តតាមបែបគុណវិស័យដូចជាការជួបសម្ភាសន៍ផ្ទាល់ជាមួយនាយកសាខាទីស្នាក់កណ្តាល ការវិភាគលើរបាយការណ៍ កម្រងឯកសារនានា វិធីសាស្រ្តស្រាវជ្រាវតាមរយៈគេហទំព័រ បណ្តាញសង្គមរបស់គ្រឹះស្ថាន ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗ បានមកពីការស្រាវជ្រាវនៅបណ្ណាល័យនៃសាកលវិទ្យាល័យវ៉ាន់ដា តាមរយៈនិក្ខេបបទ និងរបាយណ៍កម្មវិធីសិក្សាដែលបានជាស្នាដៃរបស់រៀមច្បងដោយធ្វើការដកស្រង់ និងស្វែងយល់បន្ថែមឯកសារស្រាវជ្រាវចាស់ៗ ទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ និងការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្រ្តតាមបែបគុណវិស័យដូចជាការជួបសម្ភាសន៍ផ្ទាល់ជាមួយនាយកសាខាទីស្នាក់កណ្តាល ការវិភាគលើរបាយការណ៍ កម្រងឯកសារនានា វិធីសាស្រ្តស្រាវជ្រាវតាមរយៈគេហទំព័រ បណ្តាញសង្គមរបស់គ្រឹះស្ថាន ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗបានមកពីការស្រាវជ្រាវនៅបណ្ណាល័យនៃសាកលវិទ្យាល័យវ៉ាន់ដា តាមរយៈនិក្ខេបបទ និងរបាយណ៍កម្មវិធីសិក្សា

ដែលបានជាស្នាដៃរបស់រៀមច្បងដោយធ្វើការដកស្រង់ និងស្វែងយល់បន្ថែមឯកសារស្រាវជ្រាវចាស់ៗ ទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ និងការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាទៅលើប្រធានបទការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញហិវត្ថុ អេ អឹម ខេ ភីអិលស៊ីគឺជាការស្វែងយល់ពី ទ្រឹស្តីចំណេះដឹងដែលបានមកពីការសិក្សាទ្រឹស្តីបទ បានជាបទពិសោធន៍ក្នុងការធ្វើសារណារបស់ក្រុមយើងខ្ញុំ។

ចំពោះប្រធានបទនៃសារណានេះនឹងបានផ្តល់ជាប្រយោជន៍ជាច្រើនដូចខាងក្រោម៖

- **សារៈសំខាន់សម្រាប់ស្ថានប័ន**

ជួយជាការផ្សព្វផ្សាយពាណិជ្ជកម្មសេវាកម្មជូនដល់អតិថិជន និងសាធារណជនរួមទាំងបានលើកឡើងនូវគុណសម្បិត្តដំណើរការប្រតិបត្តិការ។ បង្កើននូវភាពជឿជាក់ដល់អតិថិជនលើសេវាកម្មហិរញ្ញវត្ថុរបស់ស្ថាប័នឱ្យកាន់តែទូលំទូលាយកាន់តែសកម្ម ព្រមទាំងបានចូលរួមផ្តល់អនុសាសន៍មួយចំនួន ដែលពាក់ពន្ធ័ទៅនឹងចំណុចខ្វះខាត។ ជាឯកសារសម្រាប់ចែករំលែកពីសេវាកម្មរបស់ស្ថាប័នមួយចំណែកផងដែរ។

- **សារៈសំខាន់សម្រាប់អតិថិជន**

ជាឯកសារជំនួយដល់អតិថិជនឱ្យបានយល់ដឹងច្បាស់ពីការផ្តល់ឥណទាន ឬបានយល់ច្បាស់ពីអត្ថប្រយោជន៍នៃការប្រើប្រាស់ឥណទាន។

- **សារៈសំខាន់សម្រាប់សមាជិកស្រាវជ្រាវ**

ជួយពង្រឹងដល់សមត្ថភាពលើផ្នែកទ្រឹស្តី និងបទពិសោធន៍លើវិស័យហិរញ្ញវត្ថុ និងធនាគារ។ បង្ហាញនូវសាមគ្គីភាព និងសហការគ្នាសម្រាប់សមាជិកស្រាវជ្រាវបានផ្តល់ជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយៗយល់ដឹងពីដំណើរការនៃការផ្តល់ឥណទានទៅលើវិស័យធនាគារ។

- **សារៈសំខាន់សម្រាប់សង្គមជាតិ**

កាលណាមានការស្រាវជ្រាវកាន់តែច្រើនប្រជាពលរដ្ឋ ក៏មានចំណេះដឹងខ្ពង់ខ្ពស់កាន់តែកើនឡើងដែរ ពីព្រោះសម្បូរទៅដោយឯកសារស្រាវជ្រាវសម្រាប់យុវជនជំនាន់ក្រោយធ្វើការស្រាវជ្រាវ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានភាពរីកចម្រើនធ្វើឱ្យប្រកពទុនមានការកើនឡើងដែលជំរុញឱ្យមានការវិនិយោគកាន់តែច្រើនតាមរយៈការផ្តល់ប្រាក់កម្ចីទៅប្រជាជនសម្រាប់អាជីវកម្ម។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាទៅលើប្រធានបទការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ចែកចេញជា ៥ ជំពូកដូចខាងក្រោម៖

- **ជំពូកទី១៖** លំនាំបញ្ហានៃការស្រាវជ្រាវចំណោទបញ្ហានៃការស្រាវជ្រាវ វិធីសាស្រ្តនៃការស្រាវជ្រាវសារសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- **ជំពូកទី២៖** ការរំលឹកទ្រឹស្តីដែលមានលក្ខណៈទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរួមមាននិយមន័យនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ នីតិវិធីឥណទាន និងយុទ្ធសាស្រ្ត។ ប្រវត្តិសង្ខេបទីតាំងភូមិសាស្រ្តទ្រឹស្តី និងទស្សនៈវិស័យ គោលដៅ វប្បធម៌ការងារ នីតិវិធីនៃការផ្តល់ឥណទាន ប្រភេទនៃឥណទានយុទ្ធសាស្រ្តគ្រប់គ្រងឥណទាន និងរចនាសម្ព័ន្ធក្នុងការផ្តល់ឥណទាន។

- **ជំពូកទី៣៖** លទ្ធផលស្រាវជ្រាវដែលរួមមានស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ប្រវត្តិនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ គោលនយោបាយរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ បេសកកម្ម និងទស្សនៈវិស័យរចនាសម្ព័ន្ធរបស់គ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមប្រឹក្សាភិបាល។ គោលការណ៍នៃការផ្តល់ឥណទានខ្នាតតូច ខ្នាតមធ្យម ផលិតផលឥណទាន ការកំណត់ អត្រាការប្រាក់ ការពិន័យចំពោះការខកខានបង់សងត្រឡប់មកវិញ ទ្រព្យសម្បត្តិក្នុងការ ដាក់បញ្ចាំឬធានាឥណទាន វិធីសាស្ត្រក្នុងការសងត្រឡប់ នីតិវិធីក្នុងការផ្តល់ឥណទាន លក្ខណៈសម្បត្តិរបស់អតិថិជនដែលអាចទទួលបានឥណទាន ការវាយតម្លៃឥណទាន ការវាយតម្លៃទ្រព្យធានា ដំណោះស្រាយនៅពេលអតិថិជនសងបំណុលយឺត ឬមិនសងតាមកាលកំណត់ប្រភេទឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ លក្ខខណ្ឌតម្រូវការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ និងការរៀបចំយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងឥណទានដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការឈានទៅមុនគេ។
- **ជំពូកទី៤៖** ការវិភាគអំពីចំណុចខ្លាំង និងចំណុចខ្សោយនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ បន្ទាប់ពីបានសិក្សាស្រាវជ្រាវរួចមក។
- **ជំពូកទី៥៖** សន្និដ្ឋាន និងផ្តល់អនុសាសន៍ផ្សេងៗ អំពីចំណុចខ្វះខាតនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ។

# ជំពូកទី២
# ដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

## ២.១ លក្ខណៈនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ២.១.១ និយមន័យឥណទាន

- **ឥណទាន** (Credit) គឺជាលទ្ធភាពរបស់អ្នកក្នុងការសងបំណុល ហើយវាអាចជួយធនាគារសម្រេចចិត្តថា តើពួកគេគួរអនុញ្ញាតផ្តល់កម្ចីឱ្យអ្នកឬមិនគួរ។
- **ឥណទាន** (Credit) គឺជាការឱ្យខ្ចីប្រាក់ដែលមានចងជាកិច្ចសន្យាត្រឹមត្រូវហើយ អ្នកខ្ចីប្រាក់មានកាតព្វកិច្ចប្រើប្រាក់កម្ចីឱ្យបានស្របច្បាប់ និងសងត្រលប់មកវិញនូវប្រាក់ដើមការប្រាក់ និងបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀតដែលមាន ចែងកិច្ចសន្យាឱ្យបានទៀងទាត់។
- **ឥណទាន** (Credit) គឺជាការឱ្យអតិថិជនខ្ចីប្រាក់ ដើម្បីបំពេញសេចក្តីត្រូវការផ្សេងៗរបស់ពួកគេហើយ អតិថិជនមានកាតព្វកិច្ច សងត្រលប់មកវិញនូវប្រាក់ដើម ការប្រាក់ និងបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត។
- **ឥណទាន**(Credit) គឺជាការផ្តល់នូវចលនទ្រព្យ ឬអចលនទ្រព្យឱ្យទៅអ្នកមានតម្រូវការលើទ្រព្យទាំងនោះ ដោយតម្រូវឱ្យសងមកវិញតាមលក្ខខ័ណ្ឌមួយច្បាស់លាស់។
- **ឥណទាន** (Credit) គឺជាមធ្យោបាយដោះដូរជាមួយ នឹងការទទួលយកដោយមានដែនកំណត់។
- **ឥណទាន** (Credit) គឺជាការសន្យាសងនៅពេលអនាគតក្នុងគោលបំណង ដើម្បីទិញជំពាក់ ឬសុំខ្ចីនៅពេលបច្ចុប្បន្ន[1]។

### ២.១.២ ប្រវត្តិឥណទាន

ពាក្យ "ឥណទាន" ត្រូវបានប្រើជាលើកដំបូងនៅក្នុងភាសាអង់គ្លេសនៅទសវត្សរ៍ឆ្នាំ១៥២០ ។ ពាក្យនេះបានមក "ពីឥណទានបារាំងកណ្តាលដែលមានថា "ជំនឿ ការជឿទុកចិត្ត" បន្ទាប់មកអ៊ីតាលី ប្រើពាក្យថា ក្រេឌីតជាអក្សរឡាតាំង "ប្រាក់កម្ចី វត្ថុដែលបានប្រគល់ឱ្យភាគីផ្សេងទៀត" នៅក្នុងឆ្នាំ១៨៨១ ក្រោយមកអាមេរិកាំងក៏បានប្រើជាភាសាអង់គ្លេស "Credit" ត្រូវបានប្រើជាលើកដំបូងក្នុងឆ្នាំ១៩៥៨។

នៅសតវត្សរ៍ទី១៩ ហាងលក់ទំនិញទូទៅនៅក្នុងសហគមន៍កសិកម្ម និងរក្សាទុកសៀវភៅបញ្ជីឥណទានហាង។ កសិករនឹងទិញដោយឥណទានក្នុងកំឡុងឆ្នាំ ហើយសងបំណុលរបស់ពួកគេវិញនៅពេលប្រមូលផលបន្ទាប់ពីលក់ដំណាំរបស់ពួកគេ។

ប័ណ្ណឥណទានបានក្លាយជាចំណុចលេចធ្លោបំផុតក្នុងកំឡុងឆ្នាំ១៩០០។ ក្រុមហ៊ុនធំៗ បានចាប់ផ្តើមបង្កើតខ្សែសង្វាក់ជាមួយក្រុមហ៊ុនផ្សេងទៀត ហើយបានប្រើប័ណ្ណឥណទានជាមធ្យោបាយមួយ ដើម្បីទូទាត់ទៅឱ្យក្រុមហ៊ុនណាមួយនៃក្រុមហ៊ុនទាំងនេះ។ ក្រុមហ៊ុនបានគិតប្រាក់លើម្ចាស់ប័ណ្ណ នូវថ្លៃសេវាប្រចាំឆ្នាំជាក់លាក់មួយ ហើយជ្រើសរើសវិធីទូទាត់វិក្កយបត្ររបស់ពួកគេ ខណៈដែលក្រុមហ៊ុនដែលចូលរួមនីមួយៗត្រូវបានគិតប្រាក់ភាគរយនៃវិក្កយបត្រសរុបហើយនាំទៅដល់ការបង្កើតកាតឥណទានក្នុងនាមធនាគារជុំវិញពិភពលោក។

[1] Blogger. (2016, May 5,). *និយមន័យឥណទាន*. Retrieved June, 10 2025, from https://ocsrp.blogspot.com/2016/05/blog-post_78.html?m=1

កាតឥណទានដែលចេញដោយធនាគារដំបូងគេមួយចំនួនទៀតរួមមាន Bank of America's Bank Americand ក្នុងឆ្នាំ ១៩៥៨ និងកាត American Express របស់ American Express ក្នុងឆ្នាំ១៩៥៨។

ប័ណ្ណទាំងនេះដំណើរការស្រដៀងគ្នាទៅនឹងកាតឥណទានដែលចេញដោយក្រុមហ៊ុន។ ទោះយ៉ាងណាក៏ដោយ ពួកគេបានពង្រីកអំណាចទិញទៅស្ទើរតែគ្រប់សេវាកម្ម ហើយពួកគេបានអនុញ្ញាតឱ្យអ្នកប្រើប្រាស់ប្រមូលឥណទានបង្វិល។ ឥណទានបង្វិលគឺជាមធ្យោបាយមួយដើម្បីទូទាត់សមតុល្យនៅពេលក្រោយ ខណៈពេលដែលមានការគិតថ្លៃហិរញ្ញវត្ថុសម្រាប់សមតុល្យ[2]។

**២.១.៣ ប្រភេទនៃឥណទានសំខាន់ៗ**

ប្រភេទឥណទានសំខាន់ៗចំនួនបីគឺ ឥណទានបង្វិល ឥណទានបង់រំលស់ និងឥណទានបើកចំហ។ ឥណទានអាចឱ្យមនុស្សទិញទំនិញ ឬសេវាកម្មដោយប្រើលុយខ្ចី។ អ្នកផ្តល់ប្រាក់កម្ចីរំពឹងថានឹងទទួលបានការទូទាត់ត្រឡប់មកវិញជាមួយនឹងប្រាក់បន្ថែម (ហៅថាការប្រាក់) បន្ទាប់ពីរយៈពេលជាក់លាក់មួយ។

- **ឥណទានបង្វិល**

បន្ទាត់នៃឥណទាន គឺជាប្រភេទឥណទានដែលភ្ជាប់មកជាមួយដែនកំណត់ ហើយអាចប្រើប្រាស់រហូតដល់អ្នកឈានដល់កម្រិតដែលបានកំណត់ទុកជាមុន វាអាចរួមបញ្ចូលការទូទាត់អប្បបរមាធម្មតា ប៉ុន្តែជាធម្មតាមិនមានកាលវិភាគសងប្រាក់ថេរទេ។ ឧទាហរណ៍មួយនឹងជាប័ណ្ណឥណទាន ព្រោះវាមានដែនកំណត់ (ដែនកំណត់កាតឥណទាន) ហើយអ្នកអាចបន្តប្រើប្រាស់វារហូតទាល់តែអ្នកឈានដល់ដែនកំណត់បែបនេះ (បន្ទាប់មកថ្លៃសេវាលើសកំណត់ត្រូវបានអនុវត្តន៍)។




[2] Wikipedia. (2025, March 25). *Credit*. Retrieved June, 10 2025, from https://en.wikipedia.org/wiki/Credit

- **ឥណទានបង់រំលស់**

ប្រាក់កម្ចីបង់រំលស់ គឺជាប្រភេទឥណទានមួយទៀតដែលរួមបញ្ចូលការវិភាគទូទាត់ថេរសម្រាប់រយៈពេលជាក់លាក់មួយ ឧទាហរណ៍នៃប្រាក់កម្ចីបង់រំលស់នឹងជាប្រាក់កម្ចីរថយន្ត អ្នកត្រូវបានតម្រូវឱ្យបង់ចំនួនប្រាក់ដែលបានកំណត់នៅចន្លោះពេលកើតឡើងវិញ ( ឧទាហរណ៍ $280 ក្នុងមួយខែ ) រហូតដល់ប្រាក់កម្ចីត្រូវបានបង់ពេញ។ ឧទាហរណ៍ផ្សេងទៀតរួមមាន កម្ចីទិញផ្ទះ កម្ចីសិស្ស និងកម្ចីរយៈពេល។



- **ឥណទានបើកចំហ**

ឥណទានបើកចំហគឺជាឥណទានដែលទាមទារការទូទាត់ពេញលេញសម្រាប់រយៈពេលនីមួយៗដូចជាក្នុងមួយខែ។ អ្នកអាចខ្ចីរហូតដល់ចំនួនអតិបរិមា ដែលស្រដៀងនឹងដែនកំណត់កាតឥណទាន ប៉ុន្តែអ្នកតម្រូវឱ្យបង់លុយដែលបានខ្ចីពេញនៅចុងបញ្ចប់នៃរយៈពេលនីមួយៗ។ ឧទាហរណ៍នៃការទូទាត់សេវានានាដូចជាវិក្កយបត្របង់ថ្លៃប្រើប្រាស់ទូរស័ព្ទដែអ្នកតាមរយៈធ្វើការហៅទូរស័ព្ទ ផ្ញើសារ និងប្រើប្រាស់ទិន្នន័យជារៀងរាល់ខែ ហើយនៅចុងខែ អ្នកត្រូវបង់ប្រាក់សម្រាប់សេវាកម្មដែលអ្នកបានប្រើ (រួមទាំងថ្លៃប្រើប្រាស់បន្ថែម)។ ឧទាហរណ៍មួយទៀតគឺវិក្កយបត្រប្រើប្រាស់ (ដូចជាការប្រើប្រាស់អគ្គិសនីក្នុងគ្រួសាររបស់អ្នក)[3]។



[3] CFI Education Inc. CFI Team. *Types of Credit*. Retrieved June, 10 2025, from https://corporatefinanceinstitute.com/resources/commercial-lending/types-of-credit/

## ២.២ តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ២.២.១ និយមន័យនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ ដែលមានផ្តល់សេវាកម្មដូចជាសេវាប្រាក់សន្សំ ប្រាក់បញ្ញើ ប្រាក់កម្ចីខ្នាតតូច និងខ្នាតមធ្យមដល់ប្រជាជនក្រីក្រ និងអ្នកខ្វះដើមទុនដែលចង់សម្រួលជីវភាពខ្លួនឱ្យមានភាពប្រសើរឡើង ហើយវាក៏ជាផ្នែកមួយដែលអាចជួយកាត់បន្ថយភាពក្រីក្រដល់ប្រជាជនកម្ពុជាផងដែរ។ ជាទូទៅនៅកម្ពុជា អតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើនជាប្រជាកសិករ សហគ្រិនស្ត្រី និង ម្ចាស់សហគ្រាសធុនតូច។ បើយោងតាមធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាទាំង៧ ដែលទទួលបានអាជ្ញាប័ណ្ណស្របច្បាប់ និងអនុញ្ញាតឱ្យទទួលប្រាក់បញ្ញើពីសាធារណជនរួមមាន៖

១/ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ (PRASAC Microfinance Institution)

២/ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត

៣/គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ខូអិលធីឌី (Amret Co., Ltd or Amret Microfinance Institution)

៤/ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី (AMK MFI)

៥/ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់បែលយូប៊ី ហ្វាយនែន ឯ.ក (WB FINANCE)

៦/ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី (LOLC (Cambodia) Plc.)

៧/ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រេឌីត ភីអិលស៊ី (Kredit Plc) (សព្វថ្ងៃត្រូវបានរួមបញ្ចូលគ្នាជាមួយធនាគារហ្វីលីព / Phillip Bank Plc)[4]។

### ២.២.២ ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

វិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានចាប់ដំណើរការអំឡុងដើមទសវត្សរ៍ ឆ្នាំ១៩៩០ ហើយត្រូវបានគេបែងចែកជាបីដំណាក់កាល។ ដំណាក់កាលទាំងបី មានដំណាក់កាលចាប់ផ្តើម (១៩៩០ដល់១៩៩៥) ដំណាក់កាលស្ថាប័នអង្គការ (១៩៩៥ដល់១៩៩៩) និងដំណាក់កាលពាណិជ្ជកម្ម(១៩៩៩ដល់បច្ចុប្បន្ន)។ ក្នុងដំណាក់កាលចាប់ផ្តើមនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ប្រទេសកម្ពុជាទទួលបានជំនួយពីអង្គការអន្តរជាតិសម្រាប់ផ្តល់ឥណទានដល់ប្រជាជន និងអ្នករកស៊ីនៅតំបន់ជនបទក្រីក្រ។ ស្ថាប័នអន្តរជាតិដែលផ្តល់ជំនួយនៅពេលនោះមានដូចជា Groupe de Recherche et d'Échanges Technologiques (GRET), Catholic Relief Service (CRS), World Vision រួមជាមួយនឹង United Nations Children's Fund (UNICEF), the International Labor Organization (ILO), the United Nations Development Program (UNDP), Agence Française de Développement (AFD), និង the US Agency for International Development (USAID)។ ជំនួយហិរញ្ញប្បទាននៅពេលនោះភាគច្រើនជាសមាសធាតុឥណទាន នៅក្នុងកម្មវិធីអភិវឌ្ឍន៍ជនបទរួបរួមបញ្ចូលគ្នា។ ក្រោយមកជំនួយហិរញ្ញប្បទានរួមគ្នាខាងលើ ចាប់ផ្តើមផ្តាច់ចេញពីគ្នា ហើយមានគម្រោងមួយចំនួនបង្កើតជាស្ថាប័នអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក សម្រាប់ធ្វើសកម្មភាពទាក់ទងនឹងការបម្រើសេវាមីក្រូហិរញ្ញវត្ថុ ដែលនេះជាដំណាក់កាលស្ថាប័នអង្គការ(១៩៩៥ដល់១៩៩៩)។

ចំណែកឯដំណាក់កាលពាណិជ្ជកម្ម(១៩៩៩ដល់បច្ចុប្បន្ន) ចាប់ផ្តើមនៅពេលរដ្ឋសភាកម្ពុជាអនុម័តច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅចុងឆ្នាំ១៩៩៩ ដែលអនុញ្ញាតឱ្យអង្គការក្រៅរដ្ឋាភិបាលមួយ

[4] កាក់សេន. (2020, June 19). *និយមន័យនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*. Retrieved June, 12 2025, from https://www.facebook.com/kakcentkh/

ចំនួនអាចបន្តនិរន្តភាពរបស់ខ្លួនដោយចាប់ផ្តើមប្រែខ្លួនទៅជាធនាគារពាណិជ្ជ ឬជាក្រុមហ៊ុនឯកជនស្វែងរកប្រាក់ចំណេញ។ នៅឆ្នាំ២០០១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដំបូងគេដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ហើយមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើនទៀត ទទួលបានអាជ្ញាប័ណ្ណដំណើរការស្ថាប័នជាបន្តបន្ទាប់។ មួយឆ្នាំក្រោយមកពោលគឺនៅឆ្នាំ២០០២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុកឈានមុខគេចំនួន៧រួមមាន ស្ថាបនា អម្រឹត ហត្ថាកសិករ ម៉ាក់ស៊ីម៉ា សីលានិធិ CREDO និងប្រាសាក់ បានសម្រេចបង្កើតសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាដែលជាអង្គការក្រៅរដ្ឋាភិបាលមួយ និងសមាគមន៍វិជ្ជាជីវៈដែលមានគោលបំណងដើម្បីធានានូវភាពរុងរឿង និងនិរន្តរភាពនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។

នៅឆ្នាំ២០១២ ការិយាល័យឥណទានកម្ពុជា ត្រូវបានបង្កើតឡើងដែលក្លាយជាក្រុមហ៊ុនឈានមុខគេក្នុងការផ្តល់នូវសេវាព័ត៌មានហិរញ្ញវត្ថុ ឧបករណ៍វិភាគទិន្នន័យ និងរបាយការណ៍ឥណទានទៅដល់ស្ថាប័នហិរញ្ញវត្ថុទាំងអស់នៅក្នុងប្រទេសកម្ពុជា។ គួសបញ្ជាក់ថា សព្វថ្ងៃនេះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៨១ កំពុងដំណើរការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលក្នុងនោះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើនេះដោយផ្អែកតាមរបាយការណ៍របស់ធនាគាជាតិនៃកម្ពុជា ចេញផ្សាយកាលពីចុងឆ្នាំ២០២០ កន្លងទៅ ហើយទំហំទ្រព្យសរុបនៃវិស័យមីក្រូហិរញ្ញវត្ថុមានទំហំប្រមាណ ៣៤.៣ ទ្រីលានរៀលគិតត្រឹមឆ្នាំ២០២០កន្លងទៅ[5]។

### ២.២.៣ តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានតួនាទីចម្បងដូចខាងក្រោម៖**

- **តួនាទីអន្តរការី( The Intermediation role )**

តួនាទីនេះអនុវត្តន៍ការផ្ទេរប្រាក់សន្សំពីបណ្តាគ្រួសារ និងបង្វែរទៅជាការផ្តល់ឥណទានឱ្យទៅបណ្តាគ្រួសារ និងបុគ្គលដើម្បីធ្វើការវិនិយោគជាមួយនឹងគោលដៅបង្កើតប្រាក់ចំណេញ ឬលើកកម្ពស់ជីវភាពរស់នៅ។

- **តួនាទីជាអ្នកអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវអនុវត្តន៍តាមគោលនយោបាយរូបិយវត្ថុ និងសេដ្ឋកិច្ចរបស់រដ្ឋាភិបាលដោយចូលរួមចំណែកនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេស ការអភិវឌ្ឍសេដ្ឋកិច្ចជនបទឱ្យបានរីកចម្រើន និងបង្កើនស្តង់ដានៃការរស់នៅរបស់ពលរដ្ឋនៅក្នុងសង្គម។

- **តួនាទីអភិវឌ្ឍន៍ជនបទ(Role of Rural Development)**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានតួនាទីយ៉ាងសំខាន់ ដើម្បីជួយកាត់បន្ថយភាពក្រីក្រ និងបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់កម្ចី ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់សេវាសុខភាព ពិសេសវាជានារ៉ាប់រង និងសេវាកម្មផ្សេងៗទៀត។

**នៅក្នុងការអភិវឌ្ឍជនបទគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគឺជា៖**

- អ្នកផ្តល់កម្ចីដល់កសិករទាំងឡាយ សម្រាប់ទិញឧបករណ៍និងមធ្យោបាយកសិកម្ម។
- អ្នកផ្តល់កម្ចីឱ្យកសិករអាចរក្សាទុកនិងអាចលក់កសិផលរបស់ពួកគេនៅពេលណាដែលមានតម្លៃសមរម្យ។

[5] AMS. Mr. Heng Sovann. (2021, September 29). *យល់ដឹងពីប្រវត្តិសង្ខេបនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា*. Retrieved June, 1 2025, from https://economy.ams.com.kh/42867

- អ្នកផ្តល់កម្ចីសម្រាប់បង្កើត ពង្រីក និងកែលម្អមុខរបររបស់កសិករឱ្យបានប្រសើរឡើង។
- អ្នកផ្តល់ការហ្វឹកហ្វឺនវិជ្ជាជីវៈលើកម្មវិធីផលិតកម្មកសិកម្ម ដើម្បីឱ្យកសិករចេះរៀបចំ និងអនុវត្តន៍គម្រោងអាជីវកម្មបានត្រឹមត្រូវតាមរយៈនេះ អាចបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់កម្ចីតាមគ្រួសារ
- អ្នកកាត់បន្ថយការប្រើប្រាស់កម្ចី ដែលមានអត្រាការប្រាក់ខ្ពស់ហួសហេតុ ដែលប៉ះពាល់ដល់ស្តង់ដានៃការរស់នៅរបស់អ្នកទទួលផល។
- អ្នកបង្កើនផលិតផលក្នុងស្រុកតាមរយៈការផ្តល់សេវាហិរញ្ញវត្ថុដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ចជនបទ សេវាមីក្រូហិរញ្ញវត្ថុនៅកម្ពុជាក្នុងពេលបច្ចុប្បន្ននេះរួមមានឥណទានក្រុម ការសន្សំប្រាក់ ការហ្វឹកហ្វឺនកសាងសមត្ថភាពដល់អតិថិជនក្នុងការបង្កើតមុខរបរ ការចុះតាមដាន និងផ្តល់យោបល់ជូនអ្នកខ្ចីប្រាក់ដើម្បីឱ្យការប្រើប្រាស់មីក្រូឥណទានបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់[6]។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(MFIs) គឺជាអ្នកផ្តល់សេវាហិរញ្ញវត្ថុចម្បងសម្រាប់សេដ្ឋកិច្ចជនបទជាពិសេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើន អាចជួយដល់អ្នកជនបទក្រីក្រក្នុងការបង្កើនប្រាក់ចំណូលជួយ ដល់ប្រជាពលរដ្ឋក្នុងការផ្តល់ទុនពង្រីកមុខរបរ និងកាត់បន្ថយភាពងាយរងគ្រោះពីស្ថានការណ៍ខាងក្រៅ ដូចជាជំងឺគ្រោះមហន្តរាយផ្សេងៗ និងគ្រោះធម្មជាតិនានា ហើយក៏មានតួនាទីសំខាន់ក្នុងការជួយអភិវឌ្ឍន៍ប្រទេសកម្ពុជា និងកាត់បន្ថយភាពក្រីក្រដែរ។

ម្យ៉ាងទៀតនោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាគ្រឹះស្ថានហិរញ្ញវត្ថុខ្នាតតូច និងមធ្យមដែលផ្តល់សេវាកម្មប្រាក់សន្សំ ប្រាក់បញ្ញើ និងផ្តល់សេវាប្រាក់កម្ចីខ្នាតតូច និងខ្នាតមធ្យមទៅឱ្យប្រជាជនក្រីក្រ និងអ្នកដែលខ្វះដើមទុន ឬអ្នកបង្កើតមុខរបរថ្មី ដើម្បីឱ្យពួកគាត់មានជីវភាពល្អប្រសើរឡើង និងធ្វើឱ្យខ្លួនឯងមាននិរន្តរភាពផងដែរ។

ដូច្នេះ បើយើងមានចម្ងល់ទៅលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថា តើមានតួនាទីអ្វីខ្លះនៅក្នុងសេដ្ឋកិច្ចប្រទេសកម្ពុជា និងការរស់នៅរបស់ប្រជាពលរដ្ឋនោះ? គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានផ្តល់អត្ថប្រយោជន៍ជាច្រើន ដូចជាធ្វើឱ្យប្រជាពលរដ្ឋមានដើមទុន (ទទួលបានប្រាក់កម្ចី) ក្នុងការប្រកបរបរចិញ្ចឹមជីវិតក្នុងនោះពួកគាត់ទទួលបាននូវលទ្ធភាពក្នុងការពង្រីកអាជីវកម្ម ហើយក៏អាចជំរុញការបង្កើនប្រាក់ចំណូលក្នុងគ្រួសារឱ្យបានច្រើនជាងមុនជួយឱ្យគាត់មានជីវភាពធូរធាររួចចាកផុតពីភាពក្រីក្រ និងធ្វើឱ្យគាត់មានលទ្ធភាពបញ្ជូនកូនទៅរៀនបានទៀតផង។

បច្ចុប្បន្ន វិស័យមីក្រូហិរញ្ញវត្ថុនេះហាក់មានការប្រកួតប្រជែងកាន់តែខ្លាំងឡើង ព្រោះចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកាន់តែកើនឡើងជាបន្តបន្ទាប់ ខណៈចំនួនប្រជាជនសរុបរបស់ប្រទេសកម្ពុជាមានប្រមាណជា ១៦ លាននាក់ប៉ុណ្ណោះ។ រហូតមកទល់ពេលបច្ចុប្បន្ននេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាមានប្រមាណជាជាង ៧០ គ្រឹះស្ថាន ចំណែកប្រតិបត្តិការឥណទានវិញមានប្រមាណជាជាង២០០ផងដែរ តែជាការកត់សម្គាល់ចំពោះវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ត្រូវបានគេមើលឃើញថាមានការរីកចម្រើនគួរឱ្យចាប់អារម្មណ៍ បើប្រៀបធៀបទៅនឹងប្រទេសក្នុងតំបន់អាស៊ានដូចគ្នា[7]។

---

[6] khemsarith.wordpress.com. khemsarith. (2016, October 12). *តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*. Retrieved June, 15 2025, from https://khemsarith.wordpress.com/2016/10/12/

[7] Lareine Media. វល័ក្ខ. (2018, June 13). *គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានតួនាទីអ្វីខ្លះនៅក្នុងសេដ្ឋកិច្ចសង្គម និងការរស់នៅរបស់ពលរដ្ឋ?* Retrieved June, 15 2025, from https://lareine.com.kh/news/economy/24722/

## ២.៣ ដំណើរការនៃការសម្រេចផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ២.៣.១ និយមន័យរបស់ហិរញ្ញវត្ថុ

ហិរញ្ញវត្ថុត្រូវបានកំណត់ថាជាការគ្រប់គ្រងលុយហើយរួមបញ្ចូលនូវសកម្មភាព ដូចជា ការវិនិយោគ ការខ្ចីប្រាក់ ការផ្តល់ប្រាក់កម្ចី ថវិកា ការសន្សំ និងការព្យាករណ៍[8]។

- ហិរញ្ញវត្ថុមានបីប្រភេទសំខាន់ៗ៖ ផ្ទាល់ខ្លួន សាជីវកម្ម និង សាធារណៈរដ្ឋាភិបាល។

**១. ហិរញ្ញវត្ថុផ្ទាល់ខ្លួន (Personal Finance)** យើងហៅថាហិរញ្ញវត្ថុបែបគ្រួសារ ដែលផ្តោតសំខាន់ទៅលើការតាមដានស្ថានភាពហិរញ្ញវត្ថុក្នុងផ្ទះទាក់ទងទៅនឹងការចំណាយប្រចាំថ្ងៃ ការសន្សំលុយ ការវិនិយោគផ្ទាល់ខ្លួន ការធ្វើផែនការចូលនិវត្តន៍ ការទិញធានារ៉ាប់រងដាក់ក្នុងផ្ទះ។ ហិរញ្ញវត្ថុក្នុងផ្ទះមួយដែលខ្លាំងគឺត្រូវមានប្រភពចំណូលច្រើន មានន័យថា ចំណូលក្នុងផ្ទះមិនគួរផ្តោតទៅលើប្រាក់ខែតែមួយមុខទេជៀសវាងមានហានិភ័យនៅពេលជនបង្គោលក្នុងគ្រួសារមិនអាចបន្តធ្វើការបាន ដូច្នេះ គេអាចកាត់បន្ថយហានិភ័យតាមរយៈការវិនិយោគមានអាជីវកម្មតូចៗ ដៃគូ (ប្តីប្រពន្ធ) គួរមានរបររៀងៗខ្លួន សម្រាប់ពង្រឹងស្ថានភាពហិរញ្ញវត្ថុគ្រួសារ ។

**២. ហិរញ្ញវត្ថុសាជីវកម្ម (Corporate Finance)** ហិរញ្ញវត្ថុក្រុមហ៊ុន វាជាការផ្តោតសំខាន់ទៅលើការប្រើប្រាស់ហិរញ្ញវត្ថុរបស់ក្រុមបុគ្គលមួយក្រុមដែលដាក់លុយបញ្ចូលគ្នាដើម្បីរកស៊ីជាបច្ចេកទេសគឺ ពួកគាត់ដែលជាម្ចាស់លុយចង់ឃើញលុយដែលដាក់រកស៊ីកើនឡើងដូច្នេះហើយទើបគេថាហិរញ្ញវត្ថុសាជីវកម្មមានគោលបំណងធ្វើអោយមានអតិបរមាកម្មទ្រព្យម្ចាស់ភាគហ៊ុន (maximize shareholders' wealth) ។ ហិរញ្ញវត្ថុសាជីវកម្មផ្តោតសំខាន់ទៅលើចំណូលដែលបានពីការលក់ផលិតផល និង សេវាកម្ម និង ចំណាយទៅលើថ្លៃដើមផលិតកម្ម ថ្លៃដែលជាប់ពាក់ព័ន្ធលំហូរសាច់ប្រាក់ជាប្រចាំការប្រើប្រាស់បំណុលអោយមានប្រសិទ្ធភាពការវិនិយោគទៅលើភាគហ៊ុនក្រុមហ៊ុនដទៃទៀត...។

**៣. ហិរញ្ញវត្ថុសាធារណៈ (Public Finance)** គឺជាហិរញ្ញវត្ថុកម្រិតប្រទេសមួយដែលគេសិក្សាទៅលើចំណូល និង ចំណាយរបស់ប្រទេស។ ក្រៅពីនេះហិរញ្ញវត្ថុសាធារណៈក៏ផ្តោតទៅលើការបែងចែក និង ប្រើប្រាស់ធនធាន ក៏ដូចជាគោលនយោបាយធនាស្ថេរភាពសេដ្ឋកិច្ច (ករណីប្រទេសកម្ពុជាគឺគោលនយោបាយរូបិយវត្ថុដើម្បីធានាអត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក) ជារួមចំណូលផ្នែករដ្ឋាភិបាលត្រូវបានបែងចែកជាពីរចំណូលបានពីការប្រមូលពន្ធ និង ចំណូលមិនមែនសារពើពន្ធ (ជួលដីសម្បទាន, កម្រៃលិខិតឆ្លងដែនចំណែកចំណាយត្រូវបានបែងចែកជាចំណាយចរន្ត(បើកប្រាក់ខែមន្ត្រីរាជការ ចំណាយចំពោះមុខផ្សេងៗ...) និង ចំណាយមូលធន (ផ្តោតលើការវិនិយោគរយៈពេលវែងដូចជាការធ្វើផ្លូវ ស្ពាន ថ្នល់ជាដើម)។ ហិរញ្ញវត្ថុសាធារណៈក៏ផ្តោតទៅលើបំណុលរដ្ឋផងដែរ ក្នុងករណីខ្ចីប្រាក់ពីក្នុងស្រុកតាមរយៈការលក់ប័ណ្ណបំណុល និងខ្ចីពីប្រភពក្រៅ (ធនាគារពិភពលោក, ដៃគូអភិវឌ្ឍន៍...)[9]។

### ២.៣.២ ប្រវត្តិរបស់ហិរញ្ញវត្ថុ

ប្រភពដើមនៃហិរញ្ញវត្ថុអាចត្រូវបានគេតាមដានដល់ការចាប់ផ្តើមនៃការបង្កើតរដ្ឋ និងពាណិជ្ជកម្មក្នុងអំឡុងយុគសំរិទ្ធ។ ភស្តុតាងប្រវត្តិសាស្ត្រដំបូងបំផុតនៃហិរញ្ញវត្ថុមានចុះកាលបរិច្ឆេទប្រហែល ៣០០០ មុន

[8] CFI Education Inc. Tim Vipond, FMVA. (2019). *Finance Definition.* Retrieved June, 15 2025, from https://corporatefinanceinstitute.com/resources/wealth-management/what-is-finance-definition/

[9] CamboFinance. (2021, February14). *អ្វីទៅជាហិរញ្ញវត្ថុ?* Retrieved June, 18 2025, from https://www.facebook.com/CamboFinance/posts/pfbid024QsBh3Dv6Y7JSHuDKdwoMJvZWcbrL9iqoyZjs5w671CzSPnugVHdSrpW6uGQqa8Jl/

គ.ស ធនាគារមានដើមកំណើតនៅអាស៊ីខាងលិច ជាកន្លែងដែលប្រាសាទ និងវាំងត្រូវបានប្រើជាកន្លែងសុវត្ថិភាពសម្រាប់ការរក្សាទុកវត្ថុមានតម្លៃ។ ដំបូង វត្ថុមានតម្លៃតែមួយគត់ដែលអាចដាក់បានគឺគ្រាប់ធញ្ញជាតិ ប៉ុន្តែនៅទីបំផុត គោក្របី និងវត្ថុមានតម្លៃត្រូវបានរួមបញ្ចូល។ ក្នុងអំឡុងពេលដូចគ្នានេះ ទីក្រុង Sumerian នៃ Uruk នៅ Mesopotamia បានគាំទ្រការធ្វើពាណិជ្ជកម្មដោយការផ្តល់ប្រាក់កម្ចីក៏ដូចជាការប្រើប្រាស់ការប្រាក់ នៅក្នុង Sumerian "ការប្រាក់" គឺ mas ដែលបកប្រែជា "កំភួនជើង" ។ នៅប្រទេសក្រិក និងអេហ្ស៊ីប ពាក្យដែលប្រើសម្រាប់ការចាប់អារម្មណ៍ តូកូ និង ms រៀងគ្នាមានន័យថា "សម្រាលកូន" ។ នៅក្នុងវប្បធម៌ទាំងនេះ ការប្រាក់បង្ហាញពីការកើនឡើងដ៏មានតម្លៃ ហើយហាក់ដូចជាពិចារណាវាតាមទស្សនៈរបស់អ្នកឱ្យខ្ចី។ ក្រុមនៃហាំមូរ៉ាប៊ី (១៧៩២-១៧៥០ មុនគ.ស.) រួមបញ្ចូលច្បាប់គ្រប់គ្រងប្រតិបត្តិការធនាគារ។ ជនជាតិបាប៊ីឡូនមានទម្លាប់គិតការប្រាក់ក្នុងអត្រា ២០% ក្នុងមួយឆ្នាំ។ នៅឆ្នាំ ១២០០ មុនគ.ស. សំបកគត្រូវបានប្រើប្រាស់ជាទម្រង់ប្រាក់នៅក្នុងប្រទេសចិន។

ការប្រើប្រាស់កាក់ជាមធ្យោបាយតំណាងឱ្យប្រាក់បានចាប់ផ្តើមនៅក្នុងឆ្នាំរវាង ៧០០ និង ៥០០ មុន គ.ស. Herodotus និយាយអំពីការប្រើប្រាស់កាក់នៅលីឌាប្រហែលឆ្នាំ ៦៨៧ មុនគ.ស. ហើយនៅត្រឹមឆ្នាំ ៦៤០មុនគ.ស. ជនជាតិលីឌា បានចាប់ផ្តើមប្រើប្រាស់កាក់កាន់តែទូលំទូលាយ ហើយបានបើកហាងលក់រាយអចិន្ត្រៃយ៍។ បន្តិចក្រោយមកទីក្រុងនានាក្នុងក្រិចបុរាណដូចជា Aegina, Athens និង Corinth បានចាប់ផ្តើមជីកយកកាក់ផ្ទាល់ខ្លួនរបស់ពួកគេនៅចន្លោះឆ្នាំ៥៩៥ និង ៥៧០ BCE ។ ក្នុងអំឡុងពេលនៃសាធារណរដ្ឋរ៉ូម៉ាំង ការប្រាក់ត្រូវបានហាមឃាត់ដោយកំណែទម្រង់ Lex Genucia ក្នុងឆ្នាំ៣៤២ មុនគ.ស. នៅក្រោម Julius Caesar ពិដានលើអត្រាការប្រាក់ ១២% ត្រូវបានកំណត់ ហើយក្រោយមកទៀតនៅក្រោម Justinian វាត្រូវបានបន្ទាបបន្ថែមទៀតដល់ចន្លោះពី ៤% ទៅ ៨% [10]។

**២.៣.៣ ច្បាប់ស្តីពីដើមទុនក្នុងការបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

នៅក្នុងប្រទេសកម្ពុជាយើងបើនិយាយពីស្ថាប័ន ឬគ្រឹះស្ថានហិរញ្ញវត្ថុត្រូវបានបែងចែកជាពីរថ្នាក់គឺៈ ធនាគារកណ្តាលជាអាណាព្យាបាល (ថ្នាក់ទី១) និងបណ្តាលធនាគារពាណិជ្ជ ធនាគារឯកទេស ស្ថាប័នមីក្រូហិរញ្ញវត្ថុធនាគារស្វ័យយ័ត (ថ្នាក់ទី២)។ ធនាគារកណ្តាល ឬធនាគារជាតិ ជាស្ថាប័នសាធារណៈដែលតែងតែបោះពុម្ពរូបិយវត្ថុ គ្រប់គ្រងលើការផ្គត់ផ្គង់រូបិយវត្ថុនិងគ្រប់គ្រងអត្រាការប្រាក់ ហើយក៏ជា អាណាព្យាបាលអាជ្ញាធររូបិយវត្ថុដែលមានតួនាទីត្រិះរិះនិងដឹកនាំនយោបាយរូបិយវត្ថុដែលរាជរដ្ឋាភិបាលដាក់ឱ្យ នយោបាយឥណទាន នយោបាយប្តូរប្រាក់ នយោបាយអត្រាការប្រាក់ ព្រមទាំងមានសិទ្ធិក្នុងការ ត្រួតពិនិត្យនិងចេញបទបញ្ញត្តិនានាដល់បណ្តាគ្រឹះស្ថានហិរញ្ញវត្ថុថ្នាក់ទី២ ក្នុងគោលបំណងពង្រឹងស្ថាប័ន ហិរញ្ញវត្ថុឱ្យបានរឹងមាំក្នុងនាមជាអាណាព្យាបាល។ នៅពេលបច្ចុប្បន្ននេះធនាគារជាតិនៃកម្ពុជាបានកំណត់ អំពីដើមទុនអប្បបរមាក្នុងការបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដូចខាងក្រោមៈ

<u>**សម្រេច**</u>

**ប្រការ១** ប្រការនេះមានគោលបំណងកំណត់ឡើងវិញនូវដើមទុនចុះបញ្ជីអប្បបរមា ចំពោះគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារ។

---

[10] Wikipedia. (2025, April 19). *Finance*. Retrieved June, 18 2025, from https://en.wikipedia.org/wiki/Finance

**ប្រការ២** ប្រការនេះមានគោលបំណងពង្រឹងមូលដ្ឋានដើមទុនឱ្យកាន់តែរឹងមាំរបស់ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

**ប្រការ៣** ធនាគារពាណិជ្ជបង្កើតឡើងក្រោមរូបភាពជាសាខាធនាគារបរទេសដែលជាធនាគារមេមានចំណាត់ថ្នាក់វិនិយោគ ដោយភ្នាក់ងារចាត់ថ្នាក់ឯកទេសអន្តរជាតិត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើចំណាក់ថ្នាក់ក្រោមថ្នាក់វិនិយោគ ធនាគារត្រូវរាយការណ៍ជាបន្ទាន់មកធនាគារជាតិ។ ចំពោះធនាគារពាណិជ្ជ ជាសាខាបរទេសដែលធនាគារមិនមានចំណាត់ថ្នាក់វិនិយោគត្រូវមានដើមទុនចុះបញ្ជីក្នុងប្រការ ២០០,០០០,០០០ រៀល (ពីររយពាន់លានរៀល)។ ក្នុងករណីធនាគារមេនៅបរទេសធ្លាក់ចំណាត់ថ្នាក់ក្រោមវិនិយោគធនាគារត្រូវរាយការណ៍ជាបន្ទាន់ទៅធនាគារជាតិ។

**ប្រការ៤** ធនាគារពាណិជ្ជបង្កើតឡើងក្រោមរូបភាពជាធនាគារនៅក្នុងស្រុក ឬ ជាសម្ព័ន្ធធនាគារបរទេសត្រូវមានដើម ឬ ទុនចុះបញ្ជីអប្បបរមាស្មើនឹង ៣០០,០០០,០០០,០០០រៀល (បីរយពាន់លានរៀល)។

**ប្រការ៥** ធនាគារឯកទេសបង្កើតឡើងក្រោមរូបភាពជាធនាគារនៅក្នុងស្រុក ត្រូវមានដើមទុនចុះបញ្ជី អប្បបរមាស្មើនឹង ៦០,០០០,០០០,០០០រៀល (ហុកសិបពាន់លានរៀល)។

**ប្រការ៦**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ១២០,០០០,០០០,០០០រៀល (មួយរយម្ភៃពាន់លានរៀល)។

**ប្រការ៧**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ៦,០០០,០០០,០០០រៀល (ប្រាំមួយរយពាន់លានរៀល)។

**ប្រការ៨** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារនិងហិរញ្ញវត្ថុត្រូវបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ នៃប្រការនេះក្នុងរយៈពេលបីឆ្នាំចាប់ពីថ្ងៃចុះហត្ថ លេខា[11]។

[11] អាត គីមមុំ, សឿង ស្រីមុំ, ង៉ែត សេងហួយ, អឹម ដានីត, ប៉ាក ស្រីនាត. (២០២៣). *ដំណើរការឥណទានរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២០ ជំនាញគណនេយ្យ. ទំព័រទី៨. ៣៥ទំព័រ

# ជំពូកទី៣
# ដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## ៣.១ ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

### ៣.១.១ ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី មានប្រភពកើតចេញមកពីកម្មវិធីឥណទានខ្នាតតូច និងសន្សំរបស់អង្គការ ខុនស៊ើន វើលវ៉ាយ (Concern Worldwide) ដែលបានបង្កើតដំបូងក្នុងដើមឆ្នាំ ១៩៩០។ ក្នុងឆ្នាំ ២០០២ អង្គការ ខុនស៊ើន វើលវ៉ាយ បានសម្រេចចិត្តបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដាច់ដោយឡែកមួយ ស្ថិតក្រោមឈ្មោះថា អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជា (AMK) ដែលបន្ទាប់មកត្រូវបានគេស្គាល់ និងបានចុះបញ្ជីពាណិជ្ជកម្មជា "គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី"។ ការផ្លាស់ប្តូរក្នុងឆ្នាំ ២០០២ នេះគឺស្របគ្នានឹងការប្រែប្រួលចំពោះច្បាប់ និងបទប្បញ្ញត្តិរបស់កម្ពុជាក្នុងការគ្រប់គ្រងវិស័យមីក្រូហិរញ្ញវត្ថុ ក៏ដូចជាការវិវត្តក្នុងទីផ្សារវិស័យមីក្រូហិរញ្ញវត្ថុ។ ក្នុងខែកក្កដា ឆ្នាំ ២០០៣ គ្រឹះស្ថាន អេ អឹម ខេ បានចាប់ផ្តើមប្រតិបត្តិការដោយឯករាជ្យផ្តាច់ចេញពីអង្គការ ខុនស៊ើន ហើយបន្ទាប់មកក៏បានទទួលអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជាក្នុងឆ្នាំ ២០០៤ ដើម្បីផ្តល់សេវាមីក្រូហិរញ្ញវត្ថុពាសពេញផ្ទៃប្រទេសកម្ពុជា។

មកដល់ត្រឹមឆ្នាំ ២០០៥ គ្រឹះស្ថាន អេ អឹម ខេ ទទួលបានប្រាក់ចំណេញប្រតិបត្តិការរបស់ខ្លួនដំបូង ហើយក៏ទទួលបានការអនុម័តទទួលថវិកាជាបំណុលពីខាងក្រៅជាលើកដំបូង និងបានបង្កើតឱ្យមានយន្តការគ្រប់គ្រងលទ្ធផលការងារសង្គម។ នៅក្នុងឆ្នាំបន្ទាប់ គ្រឹះស្ថាន អេ អឹម ខេ មានកំណើនយ៉ាងឆាប់រហ័សនៅក្នុងអាជីវកម្មស្នូលរបស់ខ្លួនដោយបានពង្រីកបណ្តាញសាខាទៅកាន់គ្រប់ខេត្តក្រុងនៅក្នុងប្រទេស។ គិតត្រឹមឆ្នាំ ២០០៩ គ្រឹះស្ថានបានប្រតិបត្តិការក្នុងគ្រប់ខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា ហើយបានក្លាយខ្លួនជាគ្រឹះស្ថាន ផ្តល់កម្ចីធំជាងគេបង្អស់នៅកម្ពុជា បើយើងគិតទៅលើចំនួនអតិថិជនប្រាក់កម្ចី។

ក្នុងឆ្នាំ ២០១០ គ្រឹះស្ថាន អេ អឹម ខេ បានចាប់ផ្តើមធ្វើការកែសម្រួលជាយុទ្ធសាស្ត្រ ពីអាជីវកម្មដែលផ្តោតតែទៅលើការផ្តល់ឥណទាននៅតាមជនបទក្លាយទៅជាគ្រឹះស្ថានមួយដែលផ្តល់សេវាមីក្រូហិរញ្ញវត្ថុទូលំទូលាយជាងមុន។ យុទ្ធសាស្ត្រនេះ ព្រោះយើងចង់ឃើញ អេ អឹម ខេ ជាគ្រឹះស្ថានដែលផ្តល់នូវសេវាហិរញ្ញវត្ថុសម្បូរបែបជូនដល់ប្រជាជនក្រីក្រ ក៏ដូចជាបន្តជួយពួកគាត់កែលម្អជីវភាពរស់នៅរបស់ខ្លួន។ ដើម្បីសម្រេចគោលដៅនេះ ក្នុងឆ្នាំ២០១០ គឺជាឆ្នាំដែលជោគជ័យមួយដោយ អេ អឹម ខេទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាថាជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI)។

ក្នុងអំឡុងឆ្នាំ២០១១ និង២០១២ ជាមួយនឹងការអនុម័តយល់ព្រមពីធនាគារជាតិនៃកម្ពុជា គ្រឹះស្ថាន អេ អឹម ខេ បានចាប់ផ្តើមផ្តល់ជូននូវផលិតផលដាក់ប្រាក់បញ្ញើសន្សំទៅដល់គ្រួសារដែលមានចំណូលទាបតាមរយៈបណ្តាញភ្នាក់ងារ អេ អឹម ខេ។ សេវាកម្មនេះ ផ្តោតជាពិសេសលើគ្រួសារណាដែលពុំអាចមានលទ្ធភាពទទួលបានសេវាកម្មពីធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

ក្នុងឆ្នាំ២០១១ គ្រឹះស្ថាន អេ អឹម ខេ បានដាក់ឱ្យប្រើប្រាស់នូវសេវាផ្ទេរប្រាក់ក្នុងស្រុករបស់ខ្លួននៅគ្រប់សាខា និងភ្នាក់ងារ ជាមួយកម្រៃសេវាដែលមានភាពប្រកួតប្រជែងនៅលើទីផ្សារ។

ក្នុងឆ្នាំ២០១៣ អេ អឹម ខេ បានដាក់ដំណើរការម៉ាស៊ីន អេធីអឹម/ស៊ីឌីអឹម (ATMs/CDMs) នៅគ្រប់សាខារបស់ខ្លួន។

ក្នុងឆ្នាំ២០១៤ អេ អឹម ខេ បានចាប់ផ្តើមផ្តល់នូវសេវាធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់បុគ្គល (ដោយសហការជាមួយក្រុមហ៊ុនធានារ៉ាប់រងឯកជនធំបំផុតនៅកម្ពុជា) ដែលភ្ជាប់ទៅនឹងអតិថិជនរបស់ខ្លួនជាដំណាក់កាលសាកល្បង ដែលបន្ទាប់មកត្រូវបានពង្រីកសេវានេះទូទាំងប្រទេសក្នុងឆ្នាំ២០១៥។ ជាង ៨០% នៃអតិថិជនរបស់ អេ អឹម ខេ បច្ចុប្បន្នទទួលបានសេវាធានារ៉ាប់រងនេះ និងប្រមាណ ២៥% បានទិញសេវាធានារ៉ាប់រងបន្ថែមសម្រាប់ស្វាមី/ភរិយា/ដៃគូរបស់ពួកគេ។ ក្នុងឆ្នាំដដែលនោះ គ្រឹះស្ថាន អេ អឹម ខេ បានចាប់ផ្តើមផ្តោតសំខាន់ទៅលើវិស័យឌីជីថលផងដែរ។ គម្រោងដំបូងនៅក្នុងអាជីវកម្មរបស់យើង គឺការផ្តល់កម្ចីតាមរយៈឌីជីថល។ អេ អឹម ខេ បានអភិវឌ្ឍប្រព័ន្ធកម្ចីតាមបែបឌីជីថលដោយខ្លួនឯង ដែលអាចឱ្យមន្ត្រីឥណទានធ្វើការងារផ្តល់កម្ចីនៅតាមភូមិជាមួយអតិថិជនរបស់ខ្លួនតាមរយៈតាបប្លេត (Tablet) ចល័ត។ បច្ចុប្បន្នប្រព័ន្ធនេះ មិនត្រឹមតែផ្តល់នូវព័ត៌មានល្អប្រសើរជាងមុនប៉ុណ្ណោះទេ វាថែមទាំងធ្វើឱ្យមន្ត្រីរបស់យើងងាយស្រួលក្នុងដំណើរការផ្តល់កម្ចីនៅក្នុង អេ អឹម ខេ ដែលប្រការនេះ អាចកាត់បន្ថយការចំណាយ និងឆ្លើយតបចំពោះសេចក្តីត្រូវការរបស់អតិថិជនប្រសើរជាងមុន។

ក្នុងឆ្នាំ ២០១៩/២០២០ អេ អឹម ខេ បានដាក់បញ្ចូលប្រព័ន្ធធនាគារស្នូលថ្មីរបស់ខ្លួន និងប្រព័ន្ធស្វីដ (SWITCH) ដែលអាចឱ្យ អេ អឹម ខេ អនុវត្តន៍ប្រព័ន្ធឌីជីថលរបស់ខ្លួនកាន់តែប្រសើរជាងមុន និងឆ្លើយតបទៅនឹងការផ្លាស់ប្តូរដ៏ឆាប់រហ័សក្នុងទីផ្សារ។ ប្រព័ន្ធថ្មីនេះ បានដាក់ឱ្យដំណើរការនៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៩ នៅគ្រប់សាខា និងតំបន់ប្រតិបត្តិការទាំងអស់របស់គ្រឹះស្ថាន។ ចាប់តាំងពីពេលនោះមក អេ អឹម ខេ បានដាក់ឱ្យដំណើរការផលិតផលឌីជីថលថ្មីៗមួយចំនួន ដូចជា៖ កម្មវិធីធនាគារចល័តរបស់ អេ អឹម ខេ, អេ អឹម ខេ ផេ (ការទូទាត់តាមរយៈលេខកូដឃ្យូអ) កម្មវិធីលើទូរស័ព្ទចល័ត ណែនាំអតិថិជន ដោយធ្វើសមាហរណកម្មជាមួយភាគីទីបី ដើម្បីធ្វើការសាកល្បងសំណើរសុំកម្ចីជាលក្ខណៈឌីជីថល ដោយប្រើប្រាស់ chatbot។ លើសពីនេះ អេ អឹម ខេ បានធ្វើសមាហរណកម្មយ៉ាងពេញលេញជាមួយប្រព័ន្ធបាគង (ដែលជាបច្ចេកវិទ្យាប្លុកឆេន អនុវត្តដោយធនាគារជាតិនៃកម្ពុជា ដែលអនុញ្ញាតឱ្យធនាគារផ្សេងៗ ដែលមានអាជ្ញាប័ណ្ណអាចប្រើប្រាស់បាន), កម្ពុជាស៊ែរ ស្វិច (Cambodia Share Switch), ការទូទាត់ប្រាក់រហ័ស, និងបានធ្វើសមាហរណកម្មជាមួយអ្នកទូទាត់ប្រាក់ជាង៣០០ ទីតាំងនៅកម្ពុជា។ អេ អឹម ខេ បានដាក់ដំណើរការសេវាផ្ទេរប្រាក់ក្រៅប្រទេសដំបូងរបស់ខ្លួន ដោយមានលេខស្វីរ (Swift) និងដៃគូផ្សេងៗដូចជា ធនាគារ ខេ ប៊ី, អេ អឹម យូ, ធូន (Thunes), យូញៀនផេ (Unionpay)។

តាមប្រវត្តិសាស្ត្ររបស់ខ្លួន គ្រឹះស្ថាន អេ អឹម ខេ បានធ្វើការប្តេជ្ញាចិត្តសម្រេចគោលដៅសង្គម ហើយក្របខណ្ឌគ្រប់គ្រងលទ្ធផលសង្គមបានគ្រប់ជ្រុងជ្រោយ ដើម្បីគ្រឹះស្ថាន អេ អឹម ខេ នៅតែបន្តផ្តោតសំខាន់លើបេសកម្មរបស់ខ្លួន ក្នុងការជួយគាំទ្រដល់ប្រជាជនកម្ពុជាដែលមានចំណូលទាបជាច្រើននៅកម្ពុជា។ គិតត្រឹមខែកញ្ញា ឆ្នាំ២០២៤ អេ អឹម ខេ មានអតិថិជនសរុបជិត ១ លាននាក់ ជាមួយនឹងការិយាល័យប្រតិបត្តិការចំនួន ១៤៣ កន្លែង និងភ្នាក់ងារជិត ៧,០០០កន្លែង នៅទូទាំងប្រទេស។ អេ អឹម ខេ មានផលិតផល និងសេវាកម្មជាច្រើនកំពុងផ្តល់ជូនអតិថិជន ដូចជាសេវាប្រាក់កម្ចី ប្រាក់សន្សំ សេវាផ្ទេរប្រាក់ក្នុង និងក្រៅប្រទេស សេវាធានារ៉ាប់រងខ្នាតតូច សេវាទូទាត់វិក្កយបត្រ សេវាបើកប្រាក់បៀវត្សរ៍ សេវាបង់រំលស់ ម៉ាស៊ីនដក និង ដាក់

ប្រាក់ដោយស្វ័យប្រវត្តិ (ATMs/CDMs) ជាពិសេស គឺ AMK Mobile ប្រតិបត្តិការធនាគារលើទូរស័ព្ទដៃអាចធ្វើការទូទាត់ថ្លៃទឹក ភ្លើង សំរាម បញ្ចូលកាតទូរស័ព្ទ និងបង់វិក្កយបត្រថ្លៃទំនិញផ្សេងៗតាមរយៈការស្កេន KHQR វេរលុយទៅមករវាងធនាគារក្នុងស្រុកផ្សេងៗ តាមរយៈប្រព័ន្ធទូទាត់បាគង និងសេវាផ្សេងៗជាច្រើនទៀត។

- **គោលការណ៍ណែនាំ**
  - ❖ អេ អឹម ខេ ប្តេជ្ញាបើកទូលាយ និងឱ្យមានតម្លាភាពនូវគ្រប់ផ្នែកទាំងអស់នៃការគ្រប់គ្រង និងប្រតិបត្តិការ ។
  - ❖ អេ អឹម ខេ ប្តេជ្ញាធ្វើការអភិវឌ្ឍដំណើរការ/សេវាកម្ម និងប្រកាន់ខ្ជាប់នូវអត្តចរិត និងស្តង់ដារ ដើម្បីធានាឱ្យបាននូវការបំរើសង្គមប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយរួមទាំងការការពារអតិថិជន។
  - ❖ អេ អឹម ខេ គឺជាគ្រឹះស្ថានរៀនសូត្រ ដែលមានការផ្លាស់ប្តូរ និងការចែករំលែកនូវព័ត៌មានដ៏សមស្រប និងរួមចំណែកដល់ការអភិវឌ្ឍបុគ្គលិក ការបណ្តុះបណ្តាល ព្រមទាំងចូលរួមចំណែកក្នុងការកែលម្អគោលការណ៍ និងប្រព័ន្ធ។
  - ❖ អេ អឹម ខេ នឹងផ្តល់សេវាមីក្រូហិរញ្ញវត្ថុដល់ប្រជាជនក្រីក្រនៅក្នុងប្រទេសកម្ពុជាដែលមានមូលដ្ឋានហិរញ្ញវត្ថុរឹងមាំនៅគ្រប់កម្រិត។
- **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ មានអត្ថសញ្ញាណដូចតទៅ៖**
  - A ស្មើនឹងពាក្យថា (អង្គរ)
  - M ស្មើនឹងពាក្យថា (មីក្រូហិរញ្ញវត្ថុ)
  - K ស្មើនឹងពាក្យថា (កម្ពុជា)
  - អក្សរ A គឺជាការតំណាងឱ្យ ប្រាសាទអង្គរវត្តដែលជាប្រាង្គប្រាសាទដែលរឹងមាំ ហើយជនិមិត្តរូបរបស់ប្រទេសកម្ពុជា។
  - អក្សរ M ការតំណាងឱ្យការផ្តល់ប្រាក់កម្ចីខ្នាតមធ្យមមួយដែលអាចជាដើមទុន សម្រាប់ប្រជាកសិករ។
  - អក្សរ K ការតំណាងឱ្យ ឈ្មោះរបស់ប្រទេសកម្ពុជា ហើយសំដៅលើការផ្តល់កម្ចីនៅក្នុងស្រុក។
  - ពណ៌ស្វាយ គឺការតំណាងឱ្យភាពស្មោះត្រង់ ភក្តីភាព មហិច្ឆតា និងភាពល្អឥតខ្ចោះ។ មិនត្រឹមតែប៉ុណ្ណោះពណ៌ស្វាយក៏តំណាងឱ្យភាពច្នៃប្រឌិត សន្តិភាព និងភាពឯករាជ្យ។
  - កួរស្រូវតំណាងឱ្យការផ្តល់កម្ចីចំពោះប្រជាកសិករដែលមានជីវភាពធុនតូច និងមធ្យម។
  - ដំបូងឡើយមីក្រូហិរញ្ញវត្ថុមួយនេះមានឈ្មោះថា អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជា ដោយហៅកាត់ថា (AMK) ដោយសារតែប្រជាជននៅតាមជនបទ និងនៅតាមតំបន់ទីដាច់ស្រយោលពុំស្គាល់អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជា ព្រោះតែប្រជាពលរដ្ឋតែងតែហៅឈ្មោះកាត់របស់អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជាថា (AMK) ហេតុដូចនេះទើបអង្គរមីក្រូហិរញ្ញវត្ថុកម្ពុជាបានសម្រេចចិត្តផ្លាស់ប្តូរឈ្មោះទៅជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថា អេ អឹម ខេ ហើយមានរូបកួរស្រូវនៅកណ្តាលនៃអក្សរជាតិ និងអក្សរ បរទេសនៅឆ្នាំ ២០០៣ រហូតមកដល់ឆ្នាំ២០១៥។ បន្ទាប់មកនៅឆ្នាំ ២០១៦ ក៏សម្រេចចិត្តផ្លាស់ប្តូរ នៅផ្លាកសញ្ញាជាថ្មីម្តងទៀត គឺប្តូរកួរស្រូវមកដាក់នៅខាងក្រោមនៃអក្សរបរទេស ហើយអក្សរជាតិបានដាក់នៅខាងស្តាំបន្ទាប់ពីអក្សរបរទេស។




### ៣.១.២ គោលនយោបាយរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

#### ក.ទស្សនៈវិស័យ

ទស្សនវិស័យរយៈពេលវែងរបស់ អេ អឹម ខេ គឺដើម្បីសង្គមកម្ពុជា ដែលប្រជាពលរដ្ឋទាំងឡាយមានឱកាសគ្រប់គ្រាន់ និងស្មើភាពគ្នាក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គម ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគេ ហើយអាចជួយជាវិភាគទានយ៉ាងមានប្រយោជន៍ចំពោះការអភិវឌ្ឍប្រទេសជាតិ។

#### ខ.បេសកកម្ម

ផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងសម្បូរបែប ដល់អតិថិជនគ្រប់រូប ជាពិសេស ស្ត្រីនិងគ្រួសារដែលមានចំណូលទាប ដើម្បីជួយសម្រេចបំណងប្រាថ្នាផ្នែកហិរញ្ញវត្ថុ និងជីវភាព ដែលពួកគាត់ចង់បាន។ ជួយដល់ប្រជាពលរដ្ឋក្រីក្រភាគច្រើន ក្នុងគោលបំណង ជួយធ្វើអោយប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគេតាមរយៈការផ្តល់សេវាមីក្រូហិរញ្ញវត្ថុសមស្រប និងបិតថេរ។

## ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

### ក. រចនាសម្ព័ន្ធគ្រប់គ្រង

ក្រុមប្រឹក្សាភិបាល



លោក JOHN CON-SING YUNG



លោក CHETAN TANMAY



លោក គា បូរាណ



លោក ទិព្វ ច័ន្ទវិបុល



លោកស្រី ហេង សិតា



លោកស្រី BLANDINE CLAUDIA MARIE PONS



លោក CHENG-CHUNG



លោក CHIEN-CHIH CHENG



លោក CHIEN-LING CHENG



លោកស្រី FRANCES SINHA

# គណៈគ្រប់គ្រង



លោក គា បូរាណ



លោក សួន ពិសី



លោក សុខ កុសល



លោក LUCAS R MORO



លោកស្រី ពាំង ពិសាខ



លោក អ៊ុក កុសល

## ខ. តួនាទីគណៈគ្រប់គ្រង

**លោក JOHN CON-SING YUNG**

### ប្រធានក្រុមប្រឹក្សាភិបាល សមាជិកគណៈកម្មាធិការការងារសង្គម និងបរិស្ថាន (“SEC”) និងសមាជិកគណៈកម្មាធិការវាយតម្លៃការតែងតាំង និងអភិបាលកិច្ច (“RNCG”)

បច្ចុប្បន្ន បច្ចុប្បន្ន លោក John Con-Sing Yung ជាអភិបាលគ្រប់គ្រងនៃ The Shanghai Commercial and Savings Bank, Ltd.។ លោកធ្លាប់ជាសមាជិកក្រុមប្រឹក្សាភិបាល អគ្គនាយករងប្រតិបត្តិជាន់ខ្ពស់ និងជាប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យានៃ The Shanghai Commercial and Savings Bank, Ltd. ដែលទទួលបន្ទុកផ្នែកបច្ចេកវិទ្យាព័ត៌មានហានិភ័យ អនុលោមភាព ប្រតិបត្តិការ ច្បាប់ការពង្រីកប្រតិបត្តិការក្រៅប្រទេស ពាណិជ្ជកម្មនៅចិនដីគោក និងមានកិច្ចសហប្រតិបត្តិការជាមួយធនាគារសាជីវកម្មសៀងហៃចំនួនបី រហូតដល់ពាក់កណ្តាលឆ្នាំ២០២១។ លោកក៏កាន់មុខតំណែងជាច្រើននៅក្នុងបុត្រសម្ព័ន្ធ និងក្រុមហ៊ុនដែលពាក់ព័ន្ធផ្សេងៗទៀតរបស់ The Shanghai Commercial and Savings Bank, Ltd. លោក John បានចាប់ផ្តើមអាជីពការងាររបស់ខ្លួននៅក្នុងធនាគារ Chase Manhattan នៅទីក្រុងហុងកុងក្នុងមុខតំណែងជាសិក្ខាកាមថ្នាក់គ្រប់គ្រង ហើយបានបញ្ចប់វិញក្នុងមុខតំណែងជាអ្នកគ្រប់គ្រងក្នុងនាយកដ្ឋានគ្រប់គ្រងហានិភ័យឥណទាន។ បន្ទាប់មក លោកក៏បានចំណាយពេលវេលារបស់ខ្លួនដើម្បីបង្កើតក្រុមហ៊ុន Shenzhen Concord ដែលជាក្រុមហ៊ុនវិនិយោគរួមរវាងក្រុមហ៊ុន Canadian Eastern Finance និងរដ្ឋាភិបាលក្រុង Shenzhen។ ជាច្រើនឆ្នាំក្រោយមក លោក John បានផ្តោតលើការកសាងអាជីវកម្មបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកមុនពេលចូលបម្រើការងារជាមួយ The Shanghai Commercial and Savings Bank, Ltd. លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ និងថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្មនៅសាកលវិទ្យាល័យ Chicago ពីសហរដ្ឋអាមេរិក។

**លោក CHETAN TANMAY**

### អភិបាល សមាជិកគណៈកម្មាធិការវាយតម្លៃការតែងតាំង និងអភិបាលកិច្ច (“RNCG”) និងសមាជិកគណៈកម្មាធិការការងារសង្គម និងបរិស្ថាន (“SEC”)

លោក Chetan Tanmay ជាសហស្ថាបនិក និងប្រធាននាយកប្រតិបត្តិនៃក្រុមហ៊ុន Agora Group ជាកន្លែងដែលលោកគ្រប់គ្រងការវិនិយោគទុនភាគហ៊ុនរបស់ក្រុមហ៊ុននៅទូទាំងទ្វីបអាស៊ី និងអាហ្វ្រិក។ លោកមានបទពិសោធន៍ជាច្រើន រួមមានការផ្តល់ចំណាត់ថ្នាក់ឥណទានមីក្រូហិរញ្ញវត្ថុ ការប្រឹក្សាយោបល់ និងប្រតិបត្តិការ រួមទាំងនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ដែលលោកជាប្រធាននាយកប្រតិបត្តិ ចាប់ពីឆ្នាំ ២០០៣ ដល់ ២០០៧។ លោក Chetan Tanmay ជាសហស្ថាបនិក និងប្រធាននាយកប្រតិបត្តិនៃក្រុមហ៊ុន Agora Group ជាកន្លែងដែលលោកគ្រប់គ្រងការវិនិយោគទុនភាគហ៊ុនរបស់ក្រុមហ៊ុននៅទូទាំងទ្វីបអាស៊ី និងអាហ្វ្រិក។ លោក មានបទពិសោធន៍ជាច្រើនរួមមានការផ្តល់ចំណាត់ថ្នាក់ឥណទានមីក្រូហិរញ្ញវត្ថុ ការប្រឹក្សាយោបល់ និងប្រតិបត្តិការ រួមទាំងនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ដែលលោកជាប្រធាននាយកប្រតិបត្តិ ចាប់ពីឆ្នាំ២០០៣ ដល់ ២០០៧។ លោក បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មពី IIFM ប្រទេសឥណ្ឌា និងអនុបណ្ឌិតផ្នែករដ្ឋបាលសាធារណៈពីសាកលវិទ្យាល័យ Harvard Kennedy។

**លោក គា បូរាណ**

**អភិបាល និងប្រធាននាយកប្រតិបត្តិ**

លោក លោក គា បូរាណ ត្រូវបានតែងតាំងជាប្រធាននាយកប្រតិបត្តិនៃ អេ អឹម ខេ ក្នុងឆ្នាំ ២០១២ លោកបានចូលបម្រើការនៅ អេ អឹម ខេ អស់រយៈពេលជាង ១៥ឆ្នាំមកហើយចាប់តាំងពីឆ្នាំ ២០០៤ មក ហើយលោកបានកាន់តំណែងថ្នាក់ដឹកនាំជាច្រើន ដើម្បីចូលរួមអភិវឌ្ឍគ្រឹះស្ថានដូចជា ប្រធានផ្នែកហិរញ្ញវត្ថុ នាយកប្រតិបត្តិហិរញ្ញវត្ថុ (CFO) អនុប្រធាននាយកប្រតិបត្តិ។ មុនពេលដែលលោកចូលបម្រើការងារជាមួយ អេ អឹម ខេ លោកបានបម្រើការឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយផ្សេងទៀតក្នុងតួនាទីជានាយកគ្រប់គ្រងហិរញ្ញវត្ថុអស់រយៈពេលជាង ៤ ឆ្នាំ។ លោក បូរាណ ក៏កាន់តំណែងជាអភិបាលក្នុងស្ថាប័នផ្សេងទៀតដូចជា សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងការិយាល័យឥណទានកម្ពុជា (CBC)។ លោក បូរាណ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រហិរញ្ញវត្ថុ និងគណនេយ្យ។ លោកទទួលបានសញ្ញាបត្រជាគណនេយ្យករអាជីព ACCA (Association of Chartered Certified Accountants) ជាផ្លូវការ និងបានចូលជាសមាជិកគណនេយ្យករអាជីព ACCA ក្នុងឆ្នាំ២០០៨។

**លោក ទិព្វ ច័ន្ទវិបុល**

**អភិបាលឯករាជ្យ និងប្រធានគណៈកម្មាធិការវាយតម្លៃ តែងតាំង និងអភិបាលកិច្ច ("RNCG")**

លោកបណ្ឌិត ទិព្វ ច័ន្ទវិបុល ជាស្ថាបនិក និងជាដៃគូគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុន Tip & Partner បាននាំមកនូវបទពិសោធន៍ផ្នែកច្បាប់រយៈពេលជាង ២០ឆ្នាំដល់ក្រុមប្រឹក្សាភិបាល អេ អឹម ខេ ។ លោក គឺជាមេធាវីដែលមានអាជ្ញាប័ណ្ណ ហើយជាសមាជិកគណៈមេធាវីកម្ពុជា។ លោក បានដឹកនាំទាំងប្រតិបត្តិការខ្នាតតូច និងខ្នាតធំប្រកបដោយប្រសិទ្ធភាព ដែលពាក់ព័ន្ធនឹងអតិថិជនជារូបវន្តបុគ្គល និងនីតិបុគ្គល ខណៈពេលដែលលោកគ្រប់គ្រង និងត្រួតពិនិត្យលើការអនុវត្តច្បាប់ និងបញ្ហាច្បាប់ពាក់ព័ន្ធនានា។ ពីមុនលោកបណ្ឌិត ទិព្វ ច័ន្ទវិបុល បានធ្វើការទាំងវិស័យសាធារណៈ និងឯកជនក្នុងនាមជាអ្នកពិគ្រោះយោបល់ និងជាទីប្រឹក្សាផ្នែកច្បាប់សម្រាប់សហគ្រាសឯកជន ស្ថាប័នរដ្ឋាភិបាល ភ្នាក់ងារអន្តរជាតិនានារួមទាំងគណៈកម្មាធិការអន្តរជាតិសម្រាប់កាកបាទក្រហម ធនាគារពិភពលោក និងអង្គការសហប្រជាជាតិ។ លោកទទួលបានសញ្ញាបត្របណ្ឌិតពីសាកលវិទ្យាល័យ California Coast University សញ្ញាបត្រអនុបណ្ឌិតពីសាកលវិទ្យាល័យ Massachusetts ទីក្រុង Lowell បរិញ្ញាបត្រពីសាកលវិទ្យាល័យ Maine ទីក្រុង Presque Isle និងទទួលបានវិញ្ញាបនបត្របណ្តុះបណ្តាលច្បាប់ជាច្រើនរួមមាន The Hague Academy of International Law និងកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ និងតុលាការរបស់ JICA និងអង្គការសហប្រជាជាតិ។

**លោកស្រី ហេង សិតា**

**អភិបាលឯករាជ្យ ប្រធានគណៈកម្មាធិការសវនកម្ម និងហិរញ្ញវត្ថុ ("AFC") និងសមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ("BRC")**

លោកស្រី ហេង សិតា ជាគណនេយ្យករសាធារណៈអាជីព ហើយក៏ជាសមាជិកសកម្មនៃវិទ្យាស្ថានគណនេយ្យករសាធារណៈ និងសវនករកម្ពុជា (KICPAA) និងជាសមាជិកនៃសមាគមគណនេយ្យករអាជីព (ACCA) នៃចក្រភពអង់គ្លេស ហើយបានទទួលស្គាល់ជាសវនករផ្ទៃក្នុងអាជីពពីសហរដ្ឋអាមេរិក។ លោកស្រីបានបញ្ចប់ការសិក្សាបរិញ្ញាបត្រផ្នែកគណនេយ្យ។ លោកស្រីមានបទពិសោធន៍ជាង ១៩ ឆ្នាំ ក្នុងការគ្រប់គ្រង

សវនកម្ម និងហិរញ្ញវត្ថុ។ លោកស្រីគឺជាដៃគូគ្រប់គ្រងនៃ FII & Associates ដែលទទួលខុសត្រូវចំពោះប្រតិបត្តិការទាំងមូលរបស់ក្រុមហ៊ុនដើរតួជាដៃគូចុះហត្ថលេខានិងធានានូវគុណភាពខ្ពស់នៃសេវាកម្មដែលផ្តល់ដោយវិជ្ជាជីវៈ។ លោកស្រី ត្រូវបានបោះឆ្នោតជ្រើសរើស ធ្វើជាអនុប្រធាន និងជាប្រធាននៃ KICPAA ពីឆ្នាំ ២០១២-២០១៥ និង ២០១៥ -២០២០ បន្តបន្ទាប់គ្នា។ ពីមុនលោកស្រី សិតា ធ្លាប់ជាអ្នកឯកទេសគ្រប់គ្រងហិរញ្ញវត្ថុនៅធនាគារពិភពលោកអស់រយៈពេល៥ ឆ្នាំ និងជាអ្នកគ្រប់គ្រងសវនកម្មនៅក្នុងក្រុមហ៊ុនសវនកម្មធំមួយក្នុងចំណោមក្រុមហ៊ុនសវនកម្មធំៗទាំងបួន អស់រយៈពេល ៦ ឆ្នាំ លើការងារសេវា សវនកម្ម និងប្រឹក្សាយោបល់ក្នុងប្រទេសកម្ពុជា និងម៉ាឡេស៊ី។

**លោកស្រី BLANDINE CLAUDIA MARIE PONS**

**អភិបាលឯករាជ្យ និងប្រធានគណៈកម្មាធិការការងារសង្គម និងបរិស្ថាន (“SEC”)**

លោកស្រី **Dina** ជានាយកប្រចាំតំបន់អាស៊ីប៉ូពាំ និងជាអ្នកគ្រប់គ្រងផ្នែកការងារសង្គមរបស់គ្រឹះស្ថាន Incofin ដែលមានទីតាំងនៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ លោកស្រីក៏បានឈរឈ្មោះនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមការងារអនុវត្តការងារសង្គម (SPTF) និងជាសហប្រធានក្រុមការងារអ្នកវិនិយោគសង្គម។ លោកស្រី Dina បានគ្រប់គ្រងផលបត្រទំហំ ៨០លានដុល្លារអាមេរិក ដែលបានផ្តល់សេវាហិរញ្ញវត្ថុជាច្រើននៅទូទាំងតំបន់អាស៊ីប៉ូពាំ។ មុនពេលចូលបម្រើការងារជាមួយគ្រឹះស្ថាន Incofin លោកស្រី Dina បានរស់នៅប្រទេសហ្វីលីពីនជាកន្លែងដែលលោកស្រីធ្វើការជាអ្នកវិភាគជាន់ខ្ពស់សម្រាប់ភ្នាក់ងារផ្តល់ចំណាត់ថ្នាក់មីក្រូហិរញ្ញវត្ថុ របស់ក្រុមហ៊ុន Planet Rating។ លោកស្រី Dina ធ្លាប់រស់នៅក្នុងប្រទេសចិន ដែលនៅទីនោះលោកស្រីគឺជាសមាជិកនៃក្រុមការងាររៀបចំបង្កើត MicroCred Nanchong នៅខេត្ត Sichuan លោកស្រីក៏បានដឹកនាំគម្រោងកសាងសមត្ថភាពផងដែរ។

**លោក CHENG-CHUNG CHEN**

**អភិបាល ប្រធានគណៈកម្មាធិការទ្រព្យសកម្ម និងអសកម្ម (“BALCO”) និងសមាជិកគណៈកម្មាធិការសវកម្ម និងហិរញ្ញវត្ថុ (“AFC”)**

បច្ចុប្បន្ន លោក Cheng-Chung Chen (James) មានតួនាទីជាអនុប្រធានប្រតិបត្តិជាន់ខ្ពស់នៃការិយាល័យកាន់កាប់តំបន់ក្រៅប្រទេសនៃធនាគារ Shanghai Commercial & Savings Bank, Ltd. ទទួលបន្ទុកគ្រប់គ្រងសាខា និងការិយាល័យតំណាងនៅបរទេស។ លោក James បានបម្រើការងារនៅធនាគារ Shanghai Commercial & Savings Bank, Ltd. អស់រយៈពេលជាង ៣០ ឆ្នាំមកហើយ ពោលគឺចាប់តាំងពីឆ្នាំ១៩៩០ ហើយក្នុងអំឡុងពេលនេះ លោកក៏បានធ្វើការក្នុងមុខតំណែងជាច្រើនផ្សេងៗគ្នា។ នៅពេលចាប់ផ្តើម ការងារ លោកបានធ្វើការនៅក្នុងសាខាផ្សេងៗគ្នាអស់រយៈពេលប្រហែលជា ១២ ឆ្នាំ ដើម្បីរៀនសូត្រពីរូបិយប័ណ្ណក្នុងស្រុក អាជីវកម្មប្តូរប្រាក់ និងអាជីវកម្មពាណិជ្ជកម្មហិរញ្ញវត្ថុ។ បន្ទាប់មកលោកបានធ្វើការជាអ្នកគ្រប់គ្រងផ្នែកគណនេយ្យអស់រយៈពេលជាង ៣ ឆ្នាំ ហើយបានធ្វើជាសវនករនៅក្នុងនាយកដ្ឋានសវនកម្មនៃការិយាល័យកណ្តាលអស់រយៈពេល ៤ ខែ ដោយទទួលខុសត្រូវក្នុងការត្រួតពិនិត្យលើអនុលោមភាពនៃច្បាប់ និងបទបញ្ញត្តិ និងប្រព័ន្ធគ្រប់គ្រងផ្ទៃរបស់អាជីវកម្មនៃសាខានីមួយៗ។ បន្ទាប់មក លោកបានបម្រើការងារជាអ្នកគ្រប់គ្រងសាខាចំនួន ៣ សាខា ជាបន្តបន្ទាប់ក្នុងរយៈពេលសរុប ៨ ឆ្នាំ។ នៅឆ្នាំ២០១៦ លោកបានរៀបចំបង្កើតនាយកដ្ឋានអាជីវកម្មសន្សំ និងបម្រើការជាប្រធាននាយកដ្ឋានអាជីវកម្មសន្សំអស់រយៈពេល ៣ ឆ្នាំ។

ទំនួលខុសត្រូវចម្បងរបស់នាយកដ្ឋាននេះ គឺត្រូវគ្រប់គ្រងប្រតិបត្តិការរបស់សាខាទាំងអស់ និងវាយតម្លៃការអនុវត្តរបស់ក្រុមការងារដែលពាក់ព័ន្ធ។ ក្រោយមក លោកត្រូវបានតែងតាំងឱ្យបង្កើតសាខាដំបូងរបស់ Shanghai Commercial & Savings Bank, Ltd. (សាខា Wuxi) នៅក្នុងប្រទេសចិន ហើយបានក្លាយជាអ្នកគ្រប់គ្រងសាខាដំបូងគេ។ លោក James ក៏ជាសមាជិកដ៏សំខាន់របស់ធនាគារដែលបានចូលរួមក្នុងគម្រោងវាយតម្លៃលើការប្រឆាំងការសម្អាតប្រាក់ APG និងបានជួយធនាគារក្នុងការសម្រេចបានលទ្ធផលដ៏ល្អប្រសើរមួយ។ លោក James បានទទួលបរិញ្ញាបត្រផ្នែកធុរកិច្ចពីសាកលវិទ្យាល័យ Tamkang និងបរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យ Renmin នៃប្រទេសចិន។

**លោក CHIEN-CHIH CHENG**

**អភិបាល ប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ (“BRC”) សមាជិកគណៈកម្មាធិការទ្រព្យសកម្ម និងអសកម្ម (“BALCO”) និងសមាជិកគណៈកម្មាធិការសវនកម្ម និងហិរញ្ញវត្ថុ (“AFC”)**

បច្ចុប្បន្ន លោក CHIEN-CHIH CHENG (James) គឺជាអ្នកគ្រប់គ្រងផ្នែកគ្រប់គ្រងហានិភ័យនៃធនាគារ Shanghai Commercial & Savings Bank, Ltd. ដែលទទួលបន្ទុកលើតារាងពិន្ទុហានិភ័យឥណទាន (Credit Risk Scorecards)។ លោកជាអ្នកជំនាញក្នុងការបង្កើតគំរូនៃហានិភ័យឥណទានអាជីវកម្ម រួមទាំងកម្ចីទិញផ្ទះ ប្រាក់កម្ចីអាជីវកម្ម ប័ណ្ណឥណទាន។ ក្នុងនាមជាសមាជិក និងជាអ្នកគ្រប់គ្រងក្រុមគំរូហានិភ័យឥណទាន លោកក៏មានបទពិសោធន៍នឹងគំរូហានិភ័យឥណទានទាក់ទងនឹងផ្នែកសាជីវកម្មផងដែរ។ ជាមួយនឹងជំនាញក្នុងការធ្វើគំរូការងារផ្សេងៗ លោកបានបំពេញកាតព្វកិច្ចក្នុងការអភិវឌ្ឍន៍គំរូ IFRS9 ECL នៅពេលដែលធនាគារនៅតៃវ៉ាន់បានអនុម័ត IFRS ក្នុងឆ្នាំ២០១៨។ ចាប់ពីពេលនោះមក លោកបានគណនា និងតាមដានលទ្ធផលការចុះខ្សោយនៃផលប័ត្រប្រាក់កម្ចីជាទៀងទាត់ និងកែសម្រួលគំរូ ECL ស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច ឬតាមការផ្តល់យោបល់ណាមួយពីអ្នកជំនាញផ្ទៃក្នុង ឬខាងក្រៅ។ លោក James បានចាប់ផ្តើមអាជីពរបស់លោកក្នុងវិស័យហិរញ្ញវត្ថុជាមន្ត្រីផ្តល់ប្រាក់កម្ចី នៅធនាគារ E.Sun បន្ទាប់មកលោកបានផ្ទេរទៅក្រុមហ៊ុន E.Sun Financial Holding Company ដើម្បីអភិវឌ្ឍ និងរក្សាតារាងពិន្ទុប្រាក់កម្ចីអាជីវកម្ម (Retail Loan Scorecards)។ ប៉ុន្មានទសវត្សរ៍បន្ទាប់មក លោកបានចូលបម្រើការនៅធនាគារ Shanghai Commercial & Savings Bank, Ltd. ហើយបានធ្វើការនៅផ្នែកគំរូហានិភ័យឥណទានជាពិសេសនៅក្នុងផ្នែកអាជីវកម្ម ដើម្បីបង្កើតប្រព័ន្ធ និងវប្បធម៌វាយតម្លៃនៅក្នុងធនាគារ។ លោក James បានទទួលបរិញ្ញាបត្រផ្នែកគ្រប់គ្រងព័ត៌មានពីសាកលវិទ្យាល័យ The National Taiwan University និង បរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យ The National Chengchi University។ លោកបានបញ្ចប់ការប្រឡង Financial Risk Manager (FRM) ក្នុងឆ្នាំ ២០០៨។

**លោក CHIEN-LING CHENG**

**អភិបាល សមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ (“BRC”) និងសមាជិកគណៈកម្មាធិការទ្រព្យសកម្ម និងអសកម្ម (“BALCO”)**

បច្ចុប្បន្ន លោក CHIEN-LING CHENG (Mars) គឺជាអនុប្រធានជាន់ខ្ពស់នៃធនាគារ Shanghai Commercial & Savings Bank, Ltd. ដែលទទួលខុសត្រូវលើការប្រឆាំងការលាងលុយកខ្វក់/ប្រឆាំងការផ្តល់ហិរញ្ញប្បទានភេរវកម្ម។ លោក Mars បានចាប់ផ្តើមអាជីពរបស់លោកនៅធនាគារ Shanghai Commercial &

Savings Bank, Ltd. ចាប់ពីឆ្នាំ១៩៩០ រហូតមកដល់បច្ចុប្បន្ន។ ក្នុងអំឡុងពេលនោះ លោកបានផ្លាស់ប្តូរមុខតំណែងរបស់លោកពីអង្គភាព/នាយកដ្ឋានមួយទៅអង្គភាព/នាយកដ្ឋានផ្សេងៗជាច្រើនដូចជាបណ្តាញសាខា នាយកដ្ឋានគ្រប់គ្រងឥណទាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផ្តល់សេវាហិរញ្ញវត្ថុបុគ្គលនាយកដ្ឋានធនាគារសាជីវកម្ម នាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិ នាយកដ្ឋានអនុលោមភាព។ ហើយឥឡូវនេះលោកគឺជាប្រធាននៃ AML & CFT Center នៃ ធនាគារ Shanghai Commercial & Savings Bank, Ltd. នៅឆ្នាំ២០១៨ លោកបានតំណាងឱ្យតៃវ៉ាន់នៅក្នុងការវាយតម្លៃរបស់ APG ឆ្នាំ២០១៨ ហើយត្រូវបានទទួលការកោតសរសើរយ៉ាងខ្លាំងពីយប្រធានក្រុមវាយតម្លៃ។ ក្រៅពីនេះ លោកក៏ជាសាស្ត្រាចារ្យដ៏ល្បីល្បាញមួយរូបនៃ Taiwan Academy of Banking and Finance ដែលបង្រៀនអំពីបញ្ហា AML/CFT ចាប់ពីឆ្នាំ២០១៩ រហូតមកដល់បច្ចុប្បន្ន។ លោក Mars បានទទួលសញ្ញាប័ត្របណ្ឌិតពី Institute of Business and Management of National Yang Ming Chiao Tung University (Taiwan) ក្នុងឆ្នាំ ២០១១។

**លោកស្រី FRANCES SINHA**

**សមាជិកគណៈកម្មាធិការការងារសង្គម (“SPC”)**

លោកស្រី Frances មានជំនាញខាងផ្នែកពិគ្រោះយោបល់ លើការងារអភិវឌ្ឍអស់រយៈពេលជាង៣០ឆ្នាំក្នុងនោះមានការងារពិគ្រោះយោបល់លើវិស័យហិរញ្ញវត្ថុផងដែរ។ លោកស្រីបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ Oxford និងសាលា London School of Economics នៅចក្រភពអង់គ្លេស។ការិយាល័យរបស់លោកស្រី គឺនៅប្រទេសឥណ្ឌា ជាទីកន្លែងដែលលោកស្រីជាសហស្ថាបនិក M-CRIL ដែលជាភ្នាក់ងារជំនាញលើការវាយតម្លៃ។ លោកស្រី ធ្វើជាអ្នកក្រុមប្រឹក្សាយោបល់សម្រាប់ក្រុមការងារកិច្ចការសង្គម និងយុទ្ធនាការប្រជុំកំពូលផ្សព្វផ្សាយ MicroCredit ដោយរួមចំណែកលើរបាយការណ៍ការងារសង្គមស្តង់ដា ការគ្រប់គ្រងកិច្ចការសង្គម ការគ្រប់គ្រងលទ្ធផល លើកកម្ពស់សេវាហិរញ្ញវត្ថុដែលគាំទ្រដល់ជនក្រីក្រ និងកិច្ចការពារអតិថិជន ប្រវត្តិការងាររបស់លោកស្រីរួមមាន ការវាយតម្លៃកម្មវិធី និងការវាយតម្លៃផលប៉ះពាល់ផ្សេងៗក្នុងប្រទេសឥណ្ឌា និងនៅទូទាំងអាស៊ី។

**គណៈគ្រប់គ្រង**

**លោក គា បូរាណ**

**ប្រធាននាយកប្រតិបត្តិ**

លោក បូរាណ ត្រូវបានតែងតាំងជាប្រធាននាយកប្រតិបត្តិ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ក្នុងឆ្នាំ២០១២ ។ លោកបានចូលបម្រើការនៅ អេ អឹម ខេ អស់រយៈពេលជិត១០ ឆ្នាំមកហើយ ចាប់តាំងពីឆ្នាំ២០០៤ មក លោកបានកាន់តំណែងថ្នាក់ដឹកនាំជាច្រើន ដើម្បីចូលរួមអភិវឌ្ឍគ្រឹះស្ថានដូចជា ប្រធានផ្នែកហិរញ្ញវត្ថុ នាយកប្រតិបត្តិហិរញ្ញវត្ថុ (CFO) អនុប្រធាននាយកប្រតិបត្តិ។ មុនពេលដែលលោកចូលរួមជាមួយ អេ អឹម ខេ លោកបានធ្វើការឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយផ្សេងទៀតក្នុងតួនាទីជានាយកហិរញ្ញវត្ថុ។

លោក បូរាណ បានកាន់តំណែងជាប្រធាននាយកនៅក្នុងស្ថាប័នផ្សេងទៀតដូចជា សមាគមធនាគារកម្ពុជា សមាគមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា និងការិយាល័យឥណទានកម្ពុជា (CBC) ។ លោក បូរាណ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រហិរញ្ញវត្ថុ និងគណនេយ្យ។ លោកទទួលបានសញ្ញាប័ត្រ ជាគណនេយ្យ

កអាជីព “ACCA” (Association of Chartered Certified Accountants) ជាផ្លូវការ និងបានចូលជាសមាជិកគណនេយ្យករអាជីព “ACCA” ក្នុងឆ្នាំ២០០៨។

**លោក សួន ពិសី**

**ប្រធាននាយកប្រតិបត្តិអាជីវកម្ម**

លោក ពិសី បានចូលបម្រើការងារនៅ អេ អឹម ខេ ក្នុងឆ្នាំ២០០៩ ក្នុងតួនាទីជាប្រធានភូមិភាគ និងត្រូវបានតែងតាំងជានាយកប្រតិបត្តិឥណទាន នៅឆ្នាំ២០១២។ នៅឆ្នាំ២០១៧ លោកត្រូវបានដំឡើងតំណែងជាប្រធាននាយកប្រតិបត្តិអាជីវកម្ម ដែលលោកទទួលបន្ទុកគ្រប់គ្រងប្រតិបត្តិការអាជីវកម្មលក់រាយ ដូចជាអាជីវកម្មឥណទាន ប្រាក់សន្សំ ផ្ទេរប្រាក់ និងធានារ៉ាប់រងខ្នាតតូច។ លោកមានបទពិសោធន៍ដប់ប្រាំឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ជាមួយនឹងជំនាញដ៏ច្បាស់លាស់ ផ្នែកប្រតិបត្តិការអាជីវកម្ម សវនកម្ម អភិវឌ្ឍន៍ផលិតផល និងគ្រប់គ្រងសាខា។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស និងក្រៅប្រទេសពីមីក្រូហិរញ្ញវត្ថុជា ច្រើន។ លោក ពិសី ទទួលបានបរិញ្ញាប័ត្រ និងអនុបណ្ឌិតផ្នែកគ្រប់គ្រង ពីសាកលវិទ្យាល័យមួយនៅក្នុងទីក្រុងភ្នំពេញ។

**លោក សុខ កុសល**

**ប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា**

លោក កុសល បានចូលបម្រើការងារនៅ អេ អឹម ខេ នៅខែមេសា ឆ្នាំ២០១៥ ជាប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា។ គាត់មានបទពិសោធន៍ជាង១៤ឆ្នាំ លើវិស័យព័ត៌មានវិទ្យា ដោយកាន់តំណែងពីមន្ត្រីគាំទ្រផ្នែកបច្ចេកវិទ្យាព័ត៌មានរហូតក្លាយជាអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកបច្ចេកវិទ្យាព័ត៌មាន នៅក្រុមហ៊ុនពហុជាតិជាច្រើន។ ក្នុងដំណើរដ៏វែងឆ្ងាយដែលពោរពេញទៅដោយការប្រកួតប្រជែង និងការផ្លាស់ប្តូរលោកបានសម្របខ្លួនទៅនឹងស្ថានការទាំងនោះប្រកបដោយជោគជ័យ លោក កុសល បានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានពី INNOTECH-CBAM។

**លោក LUCAS R MORO**

**ប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ**

Lucas បានចូលបម្រើការងារនៅ អេ អឹម ខេ ជាប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុក្នុងឆ្នាំ២០២០។ លោកមានបទពិសោធន៍ជាង ១៥ឆ្នាំ ផ្នែកគណនេយ្យ នៅក្រុមហ៊ុនលក់រាយ រោងចក្រផលិតកម្មក្រុមហ៊ុនផ្តល់សេវាកម្មផ្សេងៗអង្គការក្រៅរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល។ Lucas បានកាន់តួនាទីហិរញ្ញវត្ថុជាន់ខ្ពស់ទាំងនៅក្នុងប្រទេសអូស្ត្រាលី និងប្រទេសកម្ពុជារួមទាំងជាប្រធានផ្នែករាយការណ៍ នៅក្រុមហ៊ុនចុះបញ្ជី ASX នៅអូស្ត្រាលីនិងជាប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ នៅក្រុមហ៊ុនផលិតផលអន្តរជាតិមួយនៅកម្ពុជា។

**លោកស្រី ពាំង ពិសាខ**

**ប្រធាននាយិកាប្រតិបត្តិគ្រប់គ្រងធនធានមនុស្ស និងអភិវឌ្ឍន៍**

លោកស្រី ពាំង ពិសាខ ត្រូវបានតែងតាំងជាប្រធាននាយិកាប្រតិបត្តិគ្រប់គ្រងធនធានមនុស្ស និងអភិវឌ្ឍន៍ នៅខែមករា ឆ្នាំ២០២៣ អ្នកស្រីបានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី ជាប្រធានផ្នែកបណ្តុះបណ្តាលនៅឆ្នាំ២០១១ និងត្រូវបានតែងតាំង ជានាយិកាប្រតិបត្តិបណ្តុះបណ្តាលក្នុងឆ្នាំ២០១២ និងជានាយិកាប្រតិបត្តិធនធានមនុស្សក្នុងឆ្នាំ២០១៣។ អ្នកស្រី ពិសាខ មានបទ

ពិសោធន៍ជាង២០ឆ្នាំ នៅក្នុង វិស័យផ្សេងៗគ្នាជាច្រើនរួមមាន ក្រុមហ៊ុនឯកជន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអង្គការជាតិ និងអន្តរជាតិក្នុងតួនាទីជាអ្នកបណ្តុះបណ្តាល និងគ្រប់គ្រងធនធានមនុស្ស។ បច្ចុប្បន្ននេះ អ្នកស្រី ពិសាខ ជាសមាជិកក្រុមប្រឹក្សាភិបាលសមាគមបុគ្គលិក អេ អឹម ខេ (AMK-SA) និងជាប្រធានក្លឹបធនធានមនុស្សរបស់សមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជាផងដែរ។ អ្នកស្រី ពិសាខ ទទួលបានបរិញ្ញាបត្រផ្នែកទីផ្សារ និងអនុបណ្ឌិតផ្នែកគ្រប់គ្រងពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។

**លោក អ៊ុក កុសល**

**ប្រធាននាយកប្រតិបត្តិច្បាប់ និងប្រតិបត្តិតាម**

លោក អ៊ុក កុសល ត្រូវបានតែងតាំងជាប្រធាននាយកប្រតិបត្តិច្បាប់ និងប្រតិបត្តិតាម នៅខែមករា ឆ្នាំ ២០២៣។ លោកបានចាប់ផ្តើមការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី ជានាយកប្រតិបត្តិច្បាប់ និងប្រតិបត្តិតាម កាលពីខែមេសា ឆ្នាំ២០១៨។ លោក កុសល មានបទពិសោធន៍ច្រើនជាង ១០ឆ្នាំ នៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ តាមរយៈការបំពេញការងារកន្លងមក និងការងារក្នុងពេលបច្ចុប្បន្ន លោក កុសល ទទួលបានបទពិសោធន៍វិជ្ជាជីវៈទាក់ទងនឹងការចាត់ចែងកិច្ចការផ្លូវច្បាប់របស់ក្រុមហ៊ុន កិច្ចការលេខាធិការក្រុមហ៊ុន និងកិច្ចការពាក់ព័ន្ធនឹងផ្នែកអនុលោមភាព។ លោក កុសល បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតច្បាប់ពី Transnational Laws and Business University ប្រទេសកូរ៉េខាងត្បូង។ លោក កុសល គឺជាអ្នកជំនាញប្រឆាំងការសម្អាតប្រាក់ ទទួលស្គាល់ដោយ ACAMS និង ICA។

## ៣.២. ប្រភេទឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

### ៣.២.១. ឥណទានជាក្រុម (Group Loan)

វិធីសាស្ត្រនេះ គឺផ្តល់អាទិភាពឱ្យអតិថិជនក្នុងការជ្រើសរើសក្រុមដោយខ្លួនឯង ដោយមានការកំណត់សមាជិកច្រើនបំផុត ១០០នាក់ឬ ២០ក្រុម ក្នុងមួយធនាគារភូមិ។ ប្រសិនបើអតិថិជនលើសពី១០០នាក់ឬ ២០ក្រុមក្នុងមួយធនាគារភូមិ នោះមន្ត្រីឥណទានត្រូវបំបែកធនាគារភូមិថ្មីមួយទៀត។ ចំពោះលក្ខខណ្ឌចងក្រងក្រុម គឺត្រូវមានសមាជិកចាប់ពី ២នាក់ទៅ៦នាក់ ក្នុងមួយក្រុម។

**លក្ខណៈផលិតផល និងអត្ថប្រយោជន៍**

| **លក្ខណៈផលិតផល** | **បរិយាយ** |
|---|---|
| រូបិយប័ណ្ណ | ប្រាក់រៀល |
| អត្រាការប្រាក់ | ត្រឹមតែ ១.៥០% ប៉ុណ្ណោះ |
| ទំហំកម្ចី | រហូតដល់ ៤,០០០,០០០ រៀល |
| រយៈពេលកម្ចី | រហូតដល់ ២៤ ខែ |
| របៀបបង់សង | មានភាពបទបែន (Declining,Flexi,balloon,CL) |
| ប្រភេទទ្រព្យបញ្ចាំ | មិនតម្រូវអោយមានដាក់ទ្រព្យធានា |

**លក្ខខណ្ឌ**

- តម្រូវជានាកម្ចីគ្រប់សមាជិកក្នុងក្រុម
- អតិថិជនត្រូវមានអាយុចាប់ពី ១៨ ដល់ ៧០ ឆ្នាំ
- មានអាស័យដ្ឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសកម្ពុជា

- មានប្រាក់ចំណូលទៀងទាត់ ឬអ្នករកស៊ីដែលមានប្រាក់ចំណូល

**ឯកសារតម្រូវ**

- ឯកសារបញ្ជាក់អត្តសញ្ញាណប័ណ្ណជាតិខ្មែរ / ឯកសារបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច
- ចងក្រងសមាជិកក្នុងក្រុមដោយស្ម័គ្រចិត្តចាប់ពី ២នាក់ រហូតដល់ ៦នាក់

### ៣.២.២ ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន (Personal Loan)

ជាប្រភេទ កម្ចីសម្រាប់អតិថិជនដែលមានចំណូលជាប្រភេទប្រាក់បៀវត្សជាប្រចាំខែ និង បើកប្រាក់បៀវត្សតាមរយៈគណនីសន្សំធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ ហើយមានគោលបំណងយកទៅប្រើប្រាស់ផ្ទាល់ខ្លួន ឬតម្រូវការក្នុងគ្រួសារ។

| **លក្ខណៈផលិតផល** | **បរិយាយ** |
|---|---|
| រូបិយប័ណ្ណ | ប្រាក់ដុល្លារអាមេរិក |
| ទំហំកម្ចី | រហូតដល់ ២០,០០០ដុល្លារ |
| រយៈពេលកម្ចី | រហូតដល់ ៤៨ខែ |
| អត្រាការប្រាក់ចាំខែ | ១.១០% ដល់ ១.៥០% |
| របៀបបង់សង | ប្រាក់ដើម និងការប្រាក់សងថេរប្រចាំខែ |
| ប្រភេទទ្រព្យធានា | មិនតម្រូវឱ្យមានដាក់ទ្រព្យធានា |

**លក្ខខណ្ឌ**

- អតិថិជនត្រូវមានអាយុចាប់ពី ១៨ ដល់ ៧០ ឆ្នាំ
- បម្រើការងារនៅក្នុងក្រុមហ៊ុន ឬស្ថាប័នបច្ចុប្បន្នយ៉ាងតិច៦ខែ នឹងបានបញ្ចប់ការសាកល្បងការងារ
- ត្រូវមានទីតាំងអាសយដ្ឋានរស់នៅបច្ចុប្បន្ន និងទីតាំងបម្រើការងារច្បាស់លាស់
- តម្រូវឱ្យអតិថិជនមាន AMK Mobile
- ជាបុគ្គលិកដែលមានប្រាក់ខែទៀងទាត់

**ឯកសារតម្រូវ**

- ឯកសារបញ្ជាក់អត្តសញ្ញាណប័ណ្ណជាតិខ្មែរ / ឯកសារបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច
- របាយការណ៍គណនីទទួលប្រាក់បៀវត្ស យ៉ាងតិច ៦ខែចុងក្រោយ
- លិខិតបញ្ជាក់ការងារ

**របៀបស្នើសុំកម្ចី**

- ទំនាក់ទំនងតាមរយៈ ៖ ០២៣ ២២ ០២ ០២ ឬ ១៨០០ ២០០ ២០០
- ស្នើតាមមុខងារ "Chat" លើ AMK Mobile Banking ឬ ស្កេន QR Code ខាងក្រោមនេះ

**៣.២.៣ ឥណទានខ្នាតតូចបំផុតនិងតូច** (Micro and Small Laon)

ជាប្រភេទ កម្ចីសម្រាប់អតិថិជនដែលមានកម្រិតចំណូលសមរម្យ និងមានមុខរបរច្បាស់លាស់ ហើយមានគោលបំណងយកទៅប្រើប្រាស់បង្កើនចំណូល និងប្រើប្រាស់ទូទៅក្នុងគ្រួសារ។

| **លក្ខណៈផលិតផល** | **បរិយាយ** |
|---|---|
| រូបិយប័ណ្ណ | ប្រាក់ដុល្លារអាមេរិកឬប្រាក់រៀល |
| ទំហំកម្ចី | រហូតដល់ ២០,០០០ដុល្លារ |
| រយៈពេលកម្ចី | រហូតដល់ ១២០ខែ |
| អត្រាការប្រាក់ចាំខែ | ១.១០% ដល់ ១.៥០% |
| របៀបបង់សង | Declining,Annuity,Balloon,Flexi |
| ប្រភេទទ្រព្យធានា | អចលនវត្ថុ,គណនីសន្សំ,ចលនវត្ថុ |

**លក្ខខណ្ឌ**

- អតិថិជនត្រូវមានអាយុចាប់ពី ១៨ ដល់ ៧០ ឆ្នាំ
- ត្រូវមានទីតាំងអាសយដ្ឋានរស់នៅបច្ចុប្បន្ន និងទីតាំងបម្រើការងារច្បាស់លាស់
- ជាអតិថិជនដែលមានប្រាក់ចំណូលទៀតទាត់

**ឯកសារតម្រូវ**

- ឯកសារបញ្ជាក់អត្តសញ្ញាណប័ណ្ណជាតិខ្មែរ/ឯកសារបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច
- មានរបាយការណ៍បញ្ជាក់ចំណូលត្រឹមត្រូវ

**របៀបស្នើសុំកម្ចី**

- ស្នើសុំតាមរយៈ ៖ បុគ្គលិកអេអឹមខេ ឬទីតាំងអេអឹមខេដែរនៅជិតបំផុត

**៣.២.៤ ឥណទានខ្នាតមធ្យម** (Medium Laon)

ជាប្រភេទ ឥណទានដែលផ្តោតសំខាន់ទៅលើអាជីវករ ឬម្ចាស់សហគ្រាសដែលមានបំណងចង់ពង្រីកអាជីវកម្ម ឬសហគ្រាសដែលមានស្រាប់របស់ខ្លួន។

| **លក្ខណៈផលិតផល** | **បរិយាយ** |
|---|---|
| រូបិយប័ណ្ណ | ប្រាក់ដុល្លារអាមេរិកឬប្រាក់រៀល |
| ទំហំកម្ចី | រហូតដល់ ៣០០,០០០ដុល្លារ |
| រយៈពេលកម្ចី | រហូតដល់ ១២០ខែ |
| អត្រាការប្រាក់ប្រចាំខែ | ០.៧៩% ដល់ ១.៣% |
| របៀបបង់សង | Declining,Annuity,Balloon,Flexi |
| ប្រភេទទ្រព្យធានា | អចលនវត្ថុ,គណនីសន្សំ |

**លក្ខខណ្ឌ**

- អតិថិជនត្រូវមានអាយុចាប់ពី ១៨ ដល់ ៧០ ឆ្នាំ
- ត្រូវមានទីតាំងអាសយដ្ឋានរស់នៅបច្ចុប្បន្ន និងទីតាំងបម្រើការងារច្បាស់លាស់
- ជាអតិថិជនដែលមានប្រាក់ចំណូលទៀតទាត់

**ឯកសារតម្រូវ**

- ឯកសារបញ្ជាក់អត្តសញ្ញាណប័ណ្ណជាតិខ្មែរ / ឯកសារបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច
- មានរបាយការណ៍បញ្ជាក់ចំណូលត្រឹមត្រូវ

**របៀបស្នើសុំកម្ចី**

- ស្នើសុំតាមរយៈ ៖ បុគ្គលិកអេអឹមខេ ឬទីតាំងអេអឹមខេដែរនៅជិតបំផុត

**៣.២.៥ ផលិតផលគតិសន្យាហិរញ្ញវត្ថុឡាន** (Car Leasing)

សម្រាប់ផ្តល់ជូនដល់អតិថិជនដែលមានបំណងចង់ទិញរថយន្ត សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនជាលក្ខណៈគ្រួសារ។

| **លក្ខណៈផលិតផល** | **បរិយាយ** |
|---|---|
| រូបិយប័ណ្ណ | ប្រាក់ដុល្លារអាមេរិក |
| ទំហំគតិសន្យា | រហូតដល់ ៥០,០០០ដុល្លារ |
| រយៈពេលគតិសន្យា | រហូតដល់ ៧២ខែ |
| អត្រាការប្រាក់ប្រចាំខែ | ០.៨៣% ដល់ ១.៤% |
| ទឹកប្រាក់បង់មុន | .រថយន្តថ្មី៖ ត្រូវមានទុនចូលរួមយ៉ាងតិច២០%<br>.រថយន្តមួយទឹកនាំចូលឬផ្លាកលេខ៖ ត្រូវមានទុនចូលរួមយ៉ាងតិច ១៥% |
| របៀបបង់សង | Annuity |
| ប្រភេទទ្រព្យធានា | ចលនវត្ថុ |

**លក្ខខណ្ឌ**

- អតិថិជនត្រូវមានអាយុចាប់ពី ១៨ ដល់ ៧០ ឆ្នាំ
- ជាប្រជាជនកម្ពុជាស្របច្បាប់
- មានអាស័យដ្ឋានអចិន្ត្រៃយ៍នៅតំបន់ប្រតិបត្តិការ
- មានប្រាក់ខែជាទៀងទាត់ ឬប្រាក់ចំណូលមានស្ថេរភាព
- រថយន្តថ្មី ឬមួយទឹក ( ទាំងផ្លាកលេខ និងក្រដាសពន្ធមួយទឹកដែលនាំចូល )

**ឯកសារតម្រូវ**

- ឯកសាបញ្ជាក់អត្តសញ្ញាណជាតិខ្មែរ / ឯកសារបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច
- ឯកសារផ្សេងៗដែលបញ្ជាក់ពីប្រាក់ចំណូល និងចំណាយរបស់គ្រួសារ ឬ អាជីវកម្ម
- និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំ

**របៀបស្នើសុំ៖**

លោកអ្នកគ្រាន់តែជ្រើសរើសប្រភេទរថយន្តដែលអ្នកពេញចិត្ត រួចទាក់ទងមកកាន់សេវាអតិថិជនរបស់ អេ អឹម ខេ ដើម្បីដាក់ពាក្យតាមរយៈ៖

- ហ្វេសប៊ុកផេក AMK អេ អឹម ខេ
- 023 220 202 / 1800 200 200 ( ឥតគិតថ្លៃ )

- ឬ អញ្ជើញមកកាន់ការិយាល័យណាមួយរបស់ អេ អឹម ខេ ដែលនៅជិតលោកអ្នកបំផុត។

## ៣.៣. នីតិវិធីនិងដំណើរការក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

### ក.នីតិវិធីក្នុងការផ្តល់ឥណទាន

ចំពោះនីតិវិធីក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ រួមមានបួនដំណាក់កាលដូចជា៖

- ដំណាក់កាលទី១៖ លក្ខណៈផលិតផល និងអត្ថប្រយោជន៍
- ដំណាក់កាលទី២៖ លក្ខខណ្ឌ
- ដំណាក់កាលទី៣៖ ឯកសារតម្រូវ
- ដំណាក់កាលទី៤៖ របៀបស្នើសុំកម្ចី

រូបិយប័ណ្ណសម្រាប់ផ្តល់ជូនអតិថិជនមានដូចជា ប្រាក់រៀល ប្រាក់ដុល្លារអាមេរិក ឬលុយបាត ចំពោះទំហំកម្ចីចាប់ពី ២៥០ដុល្លារ ដល់ ៣០០,០០០ ដុល្លារ រយៈពេលគិតចាប់ពី ២៤ខែ ដល់ ១២០ខែ ហើយប្រែប្រួលទៅតាមទំហំនៃប្រាក់កម្ចី អត្រាការប្រាក់ប្រចាំខែចន្លោះពី 0.៧៩%ដល់១.៥០% ។ របៀបបង់សងប្រាក់ដើមនិងការប្រាក់បង់ថេរជាប្រចាំខែនិងប្រភេទទ្រព្យធានា (អចលនវត្ថុ ចលនវត្ថុ) លក្ខណៈពិសេសមិនតម្រូវឱ្យមានទ្រព្យធានា (ឥណទានជាក្រុមនឹងឥណទានប្រើប្រាស់ផ្ទាល់ខ្លួន)។

### ខ.ដំណើរការអនុម័តឥណទាន

ដំណើរការអនុម័តឥណទានរបស់ AMK Microfinance Institution Plc. (អេ អឹម ខេ) តាមដានជាធម្មតាមានជំហានដូចខាងក្រោម៖

**១. ដំណើរការដាក់ពាក្យសុំឥណទាន**

អតិថិជនត្រូវបំពេញសំណុំបែបបទសុំឥណទានជាមួយឯកសារចាំបាច់។

ឯកសារចាំបាច់អាចរួមមាន៖ អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ ប័ណ្ណបើកគណនីធនាគារ ព័ត៌មានចំណូល និងការចំណាយ ព័ត៌មានអាជីវកម្ម (បើមាន)។

**២. ការវាយតម្លៃឥណទាន**

បុគ្គលិកឥណទាន នឹងធ្វើការវាយតម្លៃលើសមត្ថភាពសងប្រាក់របស់អតិថិជន។

ពិនិត្យលើប្រវត្តិឥណទាន ចំណូល ប្រភពចំណូល ប្រវត្តិការបង់បំណុល និងសិទ្ធិកម្មសិទ្ធិលើបន្ទុកបញ្ចាក់ (បើមាន)។

**៣. ការអនុម័ត (Approval)**

បុគ្គលិកផ្នែកឥណទាននឹងដាក់សំណើទៅក្រុមប្រឹក្សាអនុម័តឥណទាន (Credit Committee)។ ការអនុម័តអាស្រ័យលើបរិមាណប្រាក់ ប្រភេទឥណទាន និងកម្រិតហានិភ័យ។ ប្រសិនបើអនុម័ត នឹងចេញលិខិតអនុញ្ញាតឥណទាន (Credit Approval Letter)។

**៤. ការចុះហត្ថលេខា និងការផ្តល់ប្រាក់**

អតិថិជន ត្រូវចុះហត្ថលេខាលើកិច្ចសន្យាឥណទាន។ ប្រាក់ឥណទានត្រូវផ្ទេរជារូបិយវត្ថុ ឬចូលគណនីធនាគារ/វីង/ប៉េយ៍/ធប។

### ៥. ការតាមដានការបង់ប្រាក់

បុគ្គលិកតាមដានអោយអតិថិជនបង់ប្រាក់តាមកាលកំណត់។ ប្រសិនបើមានការចំរូងនឹងមានការទំនាក់ទំនងឱ្យសងបំណុល ឬរុញឱ្យបង់តាមសំណើ។

### ៣.៣.២ ប្រភេទនៃហានិភ័យ

### ១. ហានិភ័យឥណទាន

ក្រុមហ៊ុនចាត់វិធានការលើការលេចឡើងនូវហានិភ័យឥណទាន ដែលជាហានិភ័យអាចធ្វើឱ្យមានការខាតបង់ហិរញ្ញវត្ថុ ចំពោះក្រុមហ៊ុនដោយការមិនអនុវត្តនូវកាតព្វកិច្ច។ ហានិភ័យឥណទាន គឺជាហានិភ័យសំខាន់បំផុតសម្រាប់ក្រុមហ៊ុន។ ហានិភ័យឥណទានកើតឡើងជាចំបងក្នុង សកម្មភាពផ្តល់ឥណទានដែលមានចំពោះឥណទានផ្តល់ដល់អតិថិជន។ ការគ្រប់គ្រងហានិភ័យឥណទាន ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការឥណទាន។

ក. ការវាស់វែងហានិភ័យឥណទាន

ខ. ការត្រួតពិនិត្យដែនកំណត់ និងគោលនយោបាយទប់ស្កាត់នៃហានិភ័យ

គ. ការគ្រប់គ្រង កម្រិតហានិភ័យ និងគោលការណ៍បញ្ចៀសហានិភ័យ

ឃ. គោលនយោបាយក្នុងការកំណត់ឱនភាពតម្លៃ និងការធ្វើសំវិធានធន

ង. ឥណទានផ្តល់ដល់អតិថិជន

(i) ឥណទានផ្តល់ដល់អតិថិជនមិនហួសកំណត់ និងមិនខាតបង់

(ii) ឥណទានផ្តល់ដល់អតិថិជនហួសកំណត់ និងមិនខាតបង់

(iii) ឥណទានផ្តល់ដល់អតិថិជនខាតបង់

### ២. ហានិភ័យប្រតិបត្តិការ

ការខាតបង់ពីហានិភ័យប្រតិបត្តិការ ដែលអាចកើតឡើងដោយសារតែកង្វះខាត ឬបរាជ័យនៃដំណើរការផ្ទៃក្នុងធនធានមនុស្ស និងប្រព័ន្ធបច្ចេកវិជ្ជា ឬបណ្តាលមក ពីកត្តាខាងក្រៅ ត្រូវបានគ្រប់គ្រងតាមរយៈការបង្កើតឡើងនូវដំណើរការគ្រប់គ្រង ហានិភ័យប្រតិបត្តិការ ការត្រួតពិនិត្យដ៏សមស្រប និងការរាយការណ៍ពីសកម្មភាពអាជីវកម្មពីផ្នែកត្រួតពិនិត្យ និងគាំទ្រដោយឯករាជ្យពីផ្នែកអាជីវកម្ម និងការត្រួត ពិនិត្យដែលផ្តល់ដោយគណៈគ្រប់គ្រង។ ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការ តម្រូវឱ្យបង្កើតច្បាស់លាស់នូវរចនាសម្ព័ន្ធតួនាទី និងគោលនយោបាយត្រួតពិនិត្យ។ គោលនយោបាយ និងវិធានការត្រួត ពិនិត្យផ្ទៃក្នុងនីមួយៗ ត្រូវបានអនុវត្ត។ វិធានការទាំងនេះ រួមមានការបង្កើតនូវ សិទ្ធិអំណាចក្នុងការចុះហត្ថលេខា ការកំណត់ប្រព័ន្ធត្រួតពិនិត្យ ការរៀបចំនូវនីតិវិធី និងឯកសារសម្អាង។ ទាំងនេះត្រូវបានត្រួតពិនិត្យឡើងវិញជាបន្តបន្ទាប់ដើម្បីឆ្លើយតបទៅនឹងហានិភ័យប្រតិបត្តិការអាជីវកម្មមីក្រូហិរញ្ញវត្ថុ។

### ៣. ហានិភ័យទីផ្សារ

ក្រុមហ៊ុនបានប្រឈមនឹងលើការលេចឡើងនូវហានិភ័យទីផ្សារ ដែលជាហានិភ័យធ្វើឱ្យតម្លៃទីផ្សារបច្ចុប្បន្ន ឬលំហូរសាច់ប្រាក់នាអនាគតរបស់ឧបករណ៍ហិរញ្ញវត្ថុ មានការប្រែប្រួល ដោយសារតែការប្រែប្រួលតម្លៃក្នុងទីផ្សារ។ ហានិភ័យទីផ្សារកើតឡើងពីបម្រែបម្រួលនៃ អត្រាការប្រាក់ រូបិយប័ណ្ណ និងផលិតផលមូលធន ដែលទាំងអស់ នេះត្រូវប្រឈមនឹងការ បម្រែបម្រួលទីផ្សារជាក់លាក់ និងទូទៅ និងជាបម្រែបម្រួល ក្នុង

កម្រិតអស្ថិរភាពនៃអត្រា ឬតម្លៃទីផ្សារដូចជាអត្រាការប្រាក់ ការពន្យារឥណទាន អត្រាប្តូររូបិយប័ណ្ណ និងតម្លៃមូលធន។

(i) ហានិភ័យប្តូររូបិយប័ណ្ណ

(ii) ហានិភ័យតម្លៃ

(iii) ហានិភ័យអត្រាការប្រាក់

**៤ ហានិភ័យសាច់ប្រាក់ងាយស្រួល**

ហានិភ័យសាច់ប្រាក់ងាយស្រួលគឺជាហានិភ័យ ដែលក្រុមហ៊ុនមិនមាន លទ្ធភាពសងបំណុលរបស់ខ្លួន ដែលពាក់ព័ន្ធនឹងបំណុលហិរញ្ញវត្ថុ នៅពេលវាដល់ កាលកំណត់សង និងមិនមានប្រាក់បង្វិលនៅពេលគេដកប្រាក់។ មូលហេតុទាំងនេះធ្វើឱ្យក្រុមហ៊ុន ខកខានក្នុងការបំពេញកាតព្វកិច្ចសងប្រាក់បញ្ញើ ជូនអតិថិជនឱ្យបានទាន់ពេលវេលា និងខកខានក្នុងការបំពេញ កិច្ចសន្យាផ្តល់ប្រាក់កម្ចី។ គណៈគ្រប់គ្រងត្រួតពិនិត្យសាច់ប្រាក់ងាយស្រួលរបស់តារាងតុល្យការ និងគ្រប់គ្រងការប្រមូលផ្តុំ និងព័ត៌មាននៃកាលវសាន្តរបស់បំណុល។ ការត្រួតពិនិត្យ និងការរាយការណ៍ មានលក្ខណៈ ជាស្ថានភាពសាច់ប្រាក់ប្រចាំថ្ងៃ និងរៀបចំគម្រោងសម្រាប់ថ្ងៃបន្ទាប់ សប្តាហ៍បន្ទាប់ និងខែបន្ទាប់ដោយរំពឹងទុក ពីព្រោះ រយៈពេលទាំងនេះជាការិយបរិច្ឆេទ គន្លឹះដ៏សំខាន់សម្រាប់ ការគ្រប់គ្រងសាច់ប្រាក់ ងាយស្រួល។ គណៈគ្រប់គ្រងត្រួតពិនិត្យពីបម្រែបម្រួលលើម្ចាស់ប្រាក់បញ្ញើសំខាន់ៗ និងរៀបផែនការពីការដកប្រាក់របស់ពួកគេ។

**៣.៣.៣ ការបង្ការហានិភ័យ**

❖ **ការគ្រប់គងហានិភ័យឥណទាន**

គណៈកម្មាធិការឥណទានរបស់ក្រុមហ៊ុនទទួលខុសត្រូវចំពោះ ការគ្រប់គ្រងហានិភ័យឥណទានក្រុមហ៊ុនដោយៈ

- ធ្វើឱ្យប្រាកដថាក្រុមហ៊ុនមានការអនុវត្តហានិភ័យឥណទានសមស្រប រួមទាំងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ដើម្បីកំណត់ចំនួនសំវិធានធន គ្រប់គ្រាន់ស្របតាមគោលនយោបាយ និង នីតិវិធីដែលបានចែងរបស់ក្រុមហ៊ុន និងការណែនាំត្រួតពិនិត្យដែលពាក់ព័ន្ធព្រមទាំងស្តង់ដារ CIFRSs។
- កំណត់អត្តសញ្ញាណ វាយតម្លៃ និងវាស់ហានិភ័យឥណទានរបស់ក្រុមហ៊ុន ចាប់ពីឧបករណ៍ហិរញ្ញវត្ថុនីមួយៗ រហូតដល់កំរិតផលប័ត្រ។
- បង្កើតគោលនយោបាយឥណទាន ដើម្បីការពារក្រុមហ៊ុនពីហានិភ័យដែលបានកំណត់ រួមទាំងតម្រូវការដើម្បីទទួលបានវត្ថុបញ្ចាំពីអ្នកខ្ចីដើម្បីអនុវត្តការវាយតម្ល ឥណទានរបស់អ្នកខ្ចី និងដើម្បីតាមដានត្រួតពិនិត្យការប្រឈមនឹងហានិភ័យខាងក្នុងជាបន្តបន្ទាប់។
- កំណត់ការប៉ះពាល់ទៅតាមប្រភេទនៃទ្រព្យសកម្ម សមភាគី វិស័យ ការវាយតម្លៃឥណទាន ទីតាំងភូមិសាស្ត្រ។
- បង្កើតក្របខ័ណ្ឌត្រួតពិនិត្យដ៏រឹងមាំទាក់ទងនឹងរចនាសម្ព័ន្ធអនុញ្ញាតសម្រាប់ការអនុម័ត និងការបន្តផ្តល់ឥណទានហ្វាស៊ីលីធី។

- អភិវឌ្ឍ និងថែរក្សានូវការចាត់ចំណាត់ថ្នាក់ហានិភ័យ ដើម្បីចែកប្រភេទនៃការប្រឈមនឹងហានិភ័យទៅតាមកម្រិតនៃហានិភ័យនៃការខកខានក្នុងការសង។ ចំណាត់ថ្នាក់ហានិភ័យ គឺត្រូវឆ្លងកាត់ការត្រួតពិនិត្យជាប្រចាំ។
- អភិវឌ្ឍ និងថែរក្សាដំណើរការរបស់ក្រុមហ៊ុនក្នុងការវាស់ ECL រួមមានការត្រួតពិនិត្យហានិភ័យឥណទាន ការដាក់បញ្ចូលនូវព័ត៌មានព្យាករណ៍នាពេលខាងមុខនិងវិធីសាស្ត្រប្រើប្រាស់ក្នុងការវាស់ ECL។
- ធ្វើឱ្យប្រាកដថាក្រុមហ៊ុនមានគោលនយោបាយ និងនីតិវិធីក្នុងការថែរក្សា និងធ្វើឱ្យបានត្រឹមត្រូវនូវគំរូដែលត្រូវបានប្រើដើម្បីវាយតម្លៃនិងវាស់ ECL។
- បង្កើតការវាយតម្លៃគណនេយ្យ និងដំណើរការវាស់វែងហានិភ័យឥណទានដែលផ្តល់នូវមូលដ្ឋានរឹងមាំសំរាប់ប្រព័ន្ធរួម ឧបករណ៍និងទិន្នន័យដើម្បីវាយតម្ល ហានិភ័យឥណទាន និងចុះគណនេយ្យរបស់ ECL។ ការផ្តល់យោបល់ និងការណែនាំព្រមទាំងជំនាញឯកទេសដល់អង្គភាពអាជីវកម្មដើម្បីលើកកម្ពស់ការអនុវត្ត ល្អបំផុតនៅទូទាំងក្រុមហ៊ុនក្នុងការគ្រប់គ្រងហានិភ័យឥណទាន។

សវនកម្មផ្ទៃក្នុងមានមុខងារធ្វើសវនកម្មទៀងទាត់ ដើម្បីធ្វើឱ្យប្រាកដថាការគ្រប់គ្រង និងនីតិវិធីដែលបានបង្កើតឡើងត្រូវបានរៀបចំ និងអនុវត្តឱ្យត្រឹមត្រូវ។ ដូចដែលបានពន្យល់នៅក្នុងកំណត់សំគាល់ក្រុមហ៊ុនត្រួតពិនិត្យរាល់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ ដែលជាកម្មវត្ថុនៃការតម្រូវឱនភាព ដើម្បីវាយតម្លៃថាតើមានការកើនឡើងនូវហានិភ័យឥណទានជាសារវន្តចាប់តាំងពីមានការទទួលស្គាល់ដំបូង។ ប្រសិនបើមានការកើនឡើងគួរឱ្យកត់សំគាល់នៅក្នុងហានិភ័យឥណទានក្រុមហ៊ុន នឹងធ្វើការវាស់វែងសំវិធានធនខាតបង់ដោយផ្អែកលើមួយអាយុកាលរបស់វាជាជាង ECL ១២ ខែ។

### ❖ ការគ្រប់គ្រងហានិភ័យទីផ្សារ

គោលបំណងនៃហានិភ័យនៃទីផ្សាររបស់ក្រុមហ៊ុន គឺដើម្បីគ្រប់គ្រង និងត្រួតពិនិត្យការប្រឈមនឹងហានិភ័យ ទីផ្សារដើម្បីបង្កើនផលចំណេញលើហានិភ័យស្របពេលធ្វើឱ្យប្រាកដថាមានលទ្ធភាពសងបំណុល ។

ទន្ទឹមនឹងហានិភ័យសន្ទនីយភាពនេះ ALCO ទទួលខុសត្រូវក្នុងការធ្វើឱ្យប្រាកដនូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវហានិភ័យទីផ្សារទូទាំងក្រុមហ៊ុន។ កម្រិតដាក់លាក់នៃសិទ្ធិ និងការទទួលខុសត្រូវទាក់ទង នឹងការគ្រប់គ្រងហានិភ័យទីផ្សារត្រូវបានចាត់តាំងឱ្យគណៈកម្មាធិការហានិភ័យទីផ្សារតាមការសមស្រប។

**សកម្មភាពគ្រប់គ្រងហានិភ័យទីផ្សារសំខាន់ៗគឺៈ**

- ការកំណត់អត្តសញ្ញាណហានិភ័យទីផ្សារសំខាន់ៗ និងកត្តាជំរុញរបស់វា
- ការវាស់វែងឯករាជ្យ និងវាយតម្លៃលើហានិភ័យទីផ្សារសំខាន់ៗ និងកត្តាជំរុញរបស់វា
- ការប្រើប្រាស់លទ្ធផល និងការប៉ាន់ស្មានជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងហានិភ័យ / ផលទទួលបានមកវិញរបស់ក្រុមហ៊ុន; និង តាមដានហានិភ័យនិងការរាយការណ៍អំពីបញ្ហាទាំងនោះ។

ក្រុមហ៊ុនប្រើឧបករណ៍បរិមាណ និងគុណភាពជាច្រើនដើម្បីគ្រប់គ្រង និងតាមដានហានិភ័យទីផ្សារ។ ដែនកំណត់បរិមាណសម្រាប់តម្លៃសមស្រប និងភាពប្រែប្រួលលើប្រាក់ចំណូលសុទ្ធ ការធ្វើតេស្តភាពតានតឹង ការវិភាគសេណារីយ៉ូ និងសមាមាត្រលើដើមទុនសេដ្ឋកិច្ច ត្រូវបានប្រើដើម្បីពង្រឹងចំណាង់ហានិភ័យទីផ្សាររបស់ក្រុមហ៊ុន។ កត្តាបរិមាណ និងគុណភាពដែលកំណត់ហានិភ័យតម្លៃទីផ្សារ ត្រូវបានកំណត់ដោយគណៈ

គ្រប់គ្រង ALCO ដោយយោងទៅលើការគ្រប់គ្រងមូលធនសេដ្ឋកិច្ចរបស់ក្រុមហ៊ុន។ ផ្អែកលើការវិភាគគុណភាព និងសមាមាត្របរិមាណ មុខងារហានិភ័យទីផ្សារកំណត់ហានិភ័យនាពេលអនាគត រំពឹងទុក ដោយសហការជាមួយមុខងារ ហិរញ្ញវត្ថុ ការបាត់បង់ហិរញ្ញវត្ថុសក្តានុពល និងកំណត់សំណើរសម្រាប់សកម្មភាពបន្ថែមទៀតដែលត្រូវបានពិភាក្សាជាមួយអង្គភាពទីផ្សារ។ ការផ្តោតលើហានិភ័យត្រូវ បានដាក់កំហិតដោយផ្ទាល់ជាមួយនឹងដែនកំណត់ជាក់លាក់ឬត្រូវបានជៀសវាងដោយប្រយោល ដោយប្រើរចនាសម្ព័ន្ធដែនកំណត់ដូចបានពិពណ៌នាខាងលើ។ របាយការណ៍ហានិភ័យទីផ្សារដែលឆ្លុះបញ្ចាំងពីហានិភ័យរបស់ក្រុមហ៊ុន ការផ្តោតលើហានិភ័យលទ្ធផលតេស្តភាពតានតឹងត្រូវបានពិនិត្យឡើងវិញ ជារៀងរាល់ថ្ងៃ។ សកម្មភាពសមស្របត្រូវបានធ្វើឡើងនៅពេលចាំបាច់ រួមទាំងការពិនិត្យឡើងវិញនូវគោលនយោបាយគ្រប់គ្រងហានិភ័យទីផ្សារ និងដែនកំណត់ដែលពាក់ព័ន្ធដើម្បីធានា ថាគោលបំណងនៃការគ្រប់គ្រងហានិភ័យទីផ្សារត្រូវបានឆ្លើយតប។

❖ **ហានិភ័យសន្ទនីយភាព**

គណៈគ្រប់គ្រង ត្រួតពិនិត្យសាច់ប្រាក់ងាយស្រួល និងគ្រប់គ្រងការប្រមូលផ្តុំ ហើយនិងព័ត៌មាននៃកាលអវសាន្តរបស់បំណុល។ ការត្រួតពិនិត្យ និងការរាយការណ៍ មានលក្ខណៈ ជាស្ថានភាព សាច់ប្រាក់ប្រចាំថ្ងៃ និងរៀបចំគម្រោងសម្រាប់ថ្ងៃបន្ទាប់ សប្តាហ៍បន្ទាប់ និងខែបន្ទាប់ ពីព្រោះរយៈពេលទាំងនេះជាការិយបរិច្ឆេទគន្លឹះ ដ៏សំខាន់សម្រាប់ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល។ គណៈគ្រប់គ្រង ត្រួតពិនិត្យពីបម្រែបម្រួលលើម្ចាស់ប្រាក់បញ្ញើសំខាន់ៗ និងធ្វើការប៉ាន់ស្មានពីការដកប្រាក់របស់ពួកគេ។

តារាងក្នុងទំព័របន្ទាប់ គឺជាការវិភាគពីបំណុលរបស់ក្រុមហ៊ុនតាមកាលអវសាន្ត ដែលពាក់ព័ន្ធដោយផ្អែកលើការិយបរិច្ឆេទនៅសល់នាកាលបរិច្ឆេទរបាយការណ៍ ស្ថានភាពហិរញ្ញវត្ថុទៅនឹងកាលអវសាន្តក្នុងកិច្ចសន្យា ឬតាមការប៉ាន់ស្មានកាលអវសាន្ត។

❖ **ហានិភ័យដើមទុន**

យុទ្ធសាស្ត្ររបស់ក្រុមហ៊ុន គឺដើម្បីរក្សាមូលដ្ឋានមូលធនដ៏រឹងមាំដើម្បីរក្សាទំនុកចិត្តទីផ្សារ និងទ្រទ្រង់ការអភិវឌ្ឍន៍អាជីវកម្មបន្តទៀត។ ផលប៉ះពាល់នៃកម្រិតដើមទុនលើ ផលដែលបានមកវិញរបស់ម្ចាស់ភាគហ៊ុនគឺត្រូវបានទទួលស្គាល់ ហើយក្រុមហ៊ុនក៏បានទទួលស្គាល់ពីការតម្រូវនៃការរក្សាតុល្យភាពរវាងប្រាក់ចំណេញខ្ពស់ដែលអាចមកពីអត្រាជំពាក់ធំជាង និងសារៈប្រយោជន៍ និងសុវត្ថិភាពដែលទទួលបានដោយមានជំហរដើមទុនសមរម្យ។ និយ័តករនាំមុខរបស់ក្រុមហ៊ុន គឺធនាគារជាតិនៃកម្ពុជាជាអ្នកកំណត់ និងត្រួតពិនិត្យការតម្រូវដើមទុនសម្រាប់ក្រុមហ៊ុនទាំងមូល។

❖ **ការគ្រប់គ្រងហានិភ័យដើមទុន**

ដូចគ្នានឹងហានិភ័យសន្ទនីយភាព និងហានិភ័យទីផ្សារ ALCO ទទួលខុសត្រូវក្នុងការប្រាកដថាការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃហានិភ័យមូលធនទូទាំងក្រុមហ៊ុន។

ហានិភ័យដើមទុនត្រូវបានវាស់វែង និងត្រួតពិនិត្យដោយប្រើប្រាស់ការកំណត់ដែលបានគណនាស្របតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

- នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីប្រកាសស្តីពីប្រាក់ដើមបម្រុងនៅតាមស្ថាប័នធនាគារ និងហិរញ្ញវត្ថុ។

- យោងតាមមាត្រា២២ នៃប្រកាសនេះ ស្ថាប័នត្រូវអនុវត្តតាមសំវិធានធនទាក់ទងនឹង ទ្រនាប់ដើមទុនខនស៊ើរវេសិនយ៉ាងតិច ៥០ភាគរយនៃប្រាក់ទ្រនាប់ដើមទុនដែលត្រូវបន្ថែម ត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៩ និងអនុវត្តឱ្យបានពេញលេញត្រឹមថ្ងៃទី០១ ខែមករាឆ្នាំ ២០២០។
- នៅថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៨ ធនាគារជាតិនៃកម្ពុជាបានចេញសារាចរស្តីពីការអនុវត្តប្រកាសស្តីពីទ្រនាប់ដើមទុននៅតាមស្ថាប័នធនាគារ និង ហិរញ្ញវត្ថុដែលកំណត់នូវទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ក្នុងកម្រិត 0% រហូតដល់មានសេចក្តីប្រកាសថ្មីចេញ។
- នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយសេចក្តីប្រកាសលេខ ធ១៣-០២០-០០២ ដែលអនុញ្ញាតឱ្យធនាគារនិងស្ថាប័នហិរញ្ញវត្ថុ ពន្យារ និងរក្សាទ្រនាប់ដើមទុនខនស៊ើរវេសិន នៅ ៥០% ដើម្បីកាត់បន្ថយផលប៉ះពាល់ពី ជំងឺកូវីដ១៩ ទៅលើសេដ្ឋកិច្ចកម្ពុជាស្របតាមគោលនយោបាយរដ្ឋាភិបាល។

**៣.៣.៤ ការត្រួតពិនិត្យលើការបាត់បង់**

"ការត្រួតពិនិត្យលើការបាត់បង់ឥណទាន" មានន័យថា ការតាមដាន ពិនិត្យ និងវាយតម្លៃលើការបាត់បង់ឥណទានដែលអាចកើតមាន នៅក្នុងអង្គភាពហិរញ្ញវត្ថុ ឬសហគ្រាសមួយ។ វាជាដំណើរការសំខាន់ក្នុងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ។

- **ការបាត់បង់ឥណទាន (Credit Loss):** គឺជាករណីដែលអតិថិជន ឬភាគីជំពាក់មិនអាចបង់ប្រាក់ដល់សហគ្រាសបាន។

❖ **ការត្រួតពិនិត្យ៖**

- ការវាយតម្លៃសមត្ថភាពបង់ប្រាក់របស់អតិថិជនមុនពេលផ្តល់ឥណទាន
- ការបង្កើតគោលការណ៍ឥណទានយ៉ាងច្បាស់
- ការតាមដានបំណុលជាប្រចាំ
- ការប្រើប្រាស់វិធានការជំរុញការបង់ប្រាក់ឱ្យបានទាន់ពេល
- ការធានាប្រើការធានា ឬការធានារ៉ាប់រងទម្ងន់ការបាត់បង់

❖ **គោលបំណងរបស់ការត្រួតពិនិត្យលើការបាត់បង់ឥណទាន៖**

- ការកាត់បន្ថយការបាត់បង់ហិរញ្ញវត្ថុ
- ការការពារស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន
- ការបង្កើនប្រសិទ្ធភាពការគ្រប់គ្រងបំណុល

**៣.៣.៥ ការបាត់បង់ហិរញ្ញវត្ថុ**

"**ការបាត់បង់ហិរញ្ញវត្ថុរបស់មីក្រូហិរញ្ញវត្ថុ**" គឺពាក់ព័ន្ធនឹងការបរាជ័យ ឬការខាតបង់ទុនរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ (Microfinance Institutions - MFIs)។ វាអាចកើតឡើងដោយហេតុផលជាចម្បងដូចជា៖

**១. ការខាតបង់ឥណទាន (Loan default):** អតិថិជនមិនអាចសងប្រាក់កម្ចីបានតាមកំណត់។

**២. ការគ្រប់គ្រងខ្សោយ (Poor management):** ការគ្រប់គ្រងមិនមានប្រសិទ្ធភាព ឬគ្មានយុទ្ធសាស្ត្រប្រកបដោយការទប់ស្កាត់ហានិភ័យ។

**៣. ហានិភ័យទីផ្សារ (Market risks):** ការផ្លាស់ប្តូរសេដ្ឋកិច្ច ឬស្ថានភាពទីផ្សារដែលប៉ះពាល់ដល់សមត្ថភាពសងប្រាក់របស់អតិថិជន។

**៤. ហានិភ័យផ្នែកច្បាប់និងនយោបាយ (Regulatory and political risks):** ការផ្លាស់ប្តូរនយោបាយ ឬច្បាប់ដែលធ្វើឱ្យប្រតិបត្តិការស្ថាប័នមីក្រូហិរញ្ញវត្ថុពិបាកប្រតិបត្តិ។

**៥. ការលួចបន្លំ (Fraud and corruption):** ការបន្លំខាងក្នុង (អនុវត្តដោយបុគ្គលិក) ឬខាងក្រៅ។

**៦. ការបរាជ័យផ្នែកបច្ចេកវិទ្យា (Technological failures):** បច្ចេកវិទ្យារបស់ស្ថាប័នមិនគ្រប់គ្រាន់ ឬគ្មានសុវត្ថិភាព។

### ៣.៣.៦ ការកាត់បន្ថយហានិភ័យផ្ទៃក្នុង

ការកាត់បន្ថយបញ្ហាផ្ទៃក្នុងរបស់ AMK អាចធ្វើបានតាមរយៈវិធានការដូចជា៖

**១. ការកែលម្អការទំនាក់ទំនងក្នុងក្រុម៖** បង្កើនសិក្ខាសាលា ទំនាក់ទំនងជាក្រុម និងការបង្ហាញច្បាស់ពីតួនាទី/កិច្ចការរបស់បុគ្គលិកនីមួយៗ។

**២. ការគ្រប់គ្រងបុគ្គលិកល្អ៖** ធ្វើការជ្រើសរើស និងបណ្តុះបណ្តាលបុគ្គលិកអោយមានជំនាញល្អ និងមានការបង្ហាត់បង្រៀនបន្ត។

**៣. ការតាមដាននិងវាយតម្លៃប្រសិទ្ធភាពការងារ៖** ដាក់ចេញប្រព័ន្ធវាយតម្លៃ (KPIs) ដើម្បីវាស់វែងសមិទ្ធិផលនិងកែលម្អការងារ។

**៤. ការបង្កើតវប្បធម៌ស្ថាប័នល្អ៖** បង្កើតបរិយាកាសការងារដែលមានសុវត្ថិភាព មានភាពយុត្តិធម៌ និងគាំទ្របុគ្គលិក។

**៥. កំណត់ប្រព័ន្ធដោះស្រាយវិបត្តិឱ្យមានប្រសិទ្ធភាព៖** បង្កើតប្រព័ន្ធថៃទាំព័ត៌មានសម្ងាត់ បណ្តាញតំណភ្ជាប់ដើម្បីទទួលយកមតិ និងដោះស្រាយបញ្ហាបានយ៉ាងឆាប់រហ័ស។

**៦. ប្រើប្រាស់បច្ចេកវិទ្យា៖** ប្រើ software ឬប្រព័ន្ធការិយាល័យឌីជីថល ដើម្បីធ្វើឱ្យដំណើរការងារលឿន និងត្រឹមត្រូវ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយដែលប្រកាន់ជំហរយ៉ាងមុតមាំ ក្នុងការអនុវត្តការងារដោយ គោរពទៅតាមគោលការណ៍ ឬគោលនយោបាយដែលបានរៀបចំ និងអនុម័ត ដោយមានការចូលរួមពីអ្នកជំនាញការគ្រប់ផ្នែក។ រីឯនីតិវិធីនៃការផ្តល់ឥណទានលក្ខខណ្ឌ និងគោលនយោបាយនានាដែលពាក់ព័ន្ធ ក៏ត្រូវបានរៀបចំឡើងប្រកបដោយភាពជាក់លាក់ ដោយមានការចូលរួមពីអ្នកជំនាញការផ្នែកឥណទាន និងអ្នកជំនាញការផ្នែកផ្សេងៗពីនាយកដ្ឋាននានារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ផ្ទាល់ផងដែរ។

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ មានសេវាកម្មឥណទានជាច្រើនប្រភេទ ដើម្បីធ្វើការផ្តល់ជូនឬបំពេញតម្រូវការរបស់អតិថិជននាពេលបច្ចុប្បន្ននេះ។
- សេវាឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ មានលក្ខណៈលឿនរហ័ស និងអាចជឿទុកចិត្តបាន រីឯបែបបទនៃការស្នើរសុំខ្ចីឥណទានក៏មានលក្ខណៈងាយស្រួលក្នុងការបំពេញផងដែរ។
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ មាននីតិវិធីក្នុងការផ្សព្វផ្សាយព័ត៌មានឥណទានជូនទៅដល់ប្រជាពលរដ្ឋបានយ៉ាងទូលំទូលាយ និងចំតាមគោលដៅទៅតាមតំបន់ដែលប្រជាជនរស់នៅ។
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ជាគ្រឹះស្ថានដែរទទួលបាននូវទំនុកចិត្តពីអតិថិជនក្នុងការទទួលបាននៅសេវាឥណទានដ៏ល្អនឹងនឹងសុវត្ថិភាព។

## ៤.២ ការវិភាគចំណុចខ្សោយ

ទន្ទឹមនឹងភាពខ្លាំងទៅលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ក៏នៅតែមានចំណុចខ្សោយខ្លះគួរឱ្យកត់សម្គាល់ផងដែរដូចជា៖

- ការផ្តល់ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ មានផលវិបាក ព្រោះតម្រូវឱ្យអតិថិជនមាន ឯកសារច្រើនប្រភេទសម្រាប់ធ្វើការទូទាត់ ឬផ្តល់ជូនមន្ត្រីឥណទានវិញ។
- មិនមានការអនុគ្រោះទៅដល់អតិថិជនដោយបានសងត្រឡប់មកវិញយឺតយ៉ាវតាមពេលវេលាកំណត់ដែលត្រូវសងនោះទេ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១. សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការបកស្រាយខាងលើរួចមកក្រុមរបស់យើងខ្ញុំ បានយកចិត្តទុកដាក់យ៉ាងខ្លាំង ខិតខំស្រាវជ្រាវអស់រយៈពេលជាយូរជុំវិញខ្លឹមសារនៃប្រធានបទដែលបានលើកឡើងថាដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ក្រុមយើងខ្ញុំអាចធ្វើការសន្និដ្ឋានថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ គឺជាគ្រឹះស្ថានមួយក្នុងចំណោមគ្រឹះស្ថានដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានប្រភេទឥណទានជាច្រើនសម្រាប់ផ្តល់ជូនទៅដល់អតិថិជន ក្នុងគោលបំណងដើម្បីលើកកម្ពស់នូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្រីក្រ និងជំរុញសកម្មភាពសេដ្ឋកិច្ចតាមរយៈការផ្តល់ឥណទាន។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី មាននីតិវិធីនៃការផ្តល់ឥណទានជាច្រើនបែប ដើម្បីបញ្ចេញនូវផលិតផលសេវាកម្មឥណទានឱ្យទៅអតិថិជនរបស់ខ្លួនបានច្រើនបំផុត ហើយមានគុណភាព និងប្រសិទ្ធភាពខ្ពស់នោះគ្រឹះស្ថានខិតខំបណ្តុះបណ្តាលបុគ្គលិកខាងផ្នែកឥណទានទាំងអស់ ក្នុងគោលបំណងក្លាយជាអាជីពច្បាស់លាស់តាំងពីការផ្តល់ប្រាក់កម្ចីរហូតពេលប្រមូលមកវិញបានគ្រប់ចំនួននិមានសុវត្ថិភាពទៀតហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ មាននិតិវិធីនៃការផ្តល់ឥណទានដូច ការជាប្រមូលប្រាក់សង ការផ្សព្វផ្សាយអំពីផលិតផល ការវិភាគលើអាកប្បកិរិយានិងទ្រព្យបញ្ចាំ។

ដោយសារសម្មិទ្ធិផលទាំងអស់ដែលកើតចេញពីការខិតខំតស៊ូ និងព្យាយាមកន្លងមកជាពិសេសការប្រើប្រាស់គំនិតថ្មីៗ ប្រាជ្ញា ស្វ័យគ្រប់គ្រងរបស់ខ្លួន ដោយស្មារតីម្ចាស់ការឈរលើទស្សនៈម៉ឺងម៉ាត់ ប្រាកដនិយមបានជំរុញឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ទទួលបាននូវស្នាដៃដែលជាលទ្ធផល ផ្លែផ្កាវិជ្ជមាន ដូចសព្វថ្ងៃនេះ។ សរុបសេចក្តីមកក្រុមយើងខ្ញុំ អាចសន្និដ្ឋានបានថា ទោះបីជាមានការអនុវត្តន៍ និងការប្រែយ៉ាងណាក្តីក៏នៅមាននូវចំណុចខ្វះមួយចំនួនដែលមិនអាចចៀសផុតបានដែរ។ អាស្រ័យហេតុនេះហើយ បានជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ នៅតែមានការខិតខំស្វែងរកមធ្យោបាយដើម្បីធ្វើឱ្យគ្រឹះស្ថានរបស់ខ្លួនកាន់តែមានភាពល្អប្រសើរឡើងបន្ថែមទៀត។

## ៥.២ ការផ្តល់អនុសាសន៍

តាមការចុះកម្មសិក្សា និងការស្រាវជ្រាវកន្លងមកនូវគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ក្រុមយើងខ្ញុំបានសង្កេតឃើញថាប្រធានបទនៃដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ នូវតែមានចំណុចខ្វះខាតគួរតែកែលម្អ ដូចនេះហើយក្រុមយើងខ្ញុំសុំផ្តល់ជាមតិយោបល់មួយចំនួនក្នុងគោលបំណងស្ថាបនាទៅដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ដូចតទៅ៖

- រយៈពេលការអនុគ្រោះគួរតែផ្តល់ជូនទៅដល់អតិថិជននៅពេលមានការសងត្រឡប់មកវិញយឺតយ៉ាវ ឬមិនតាមពេលវេលាដែលបានកំណត់សង។
- ក្នុងកំឡុងពេលបញ្ចេញឥណទានតម្រូវឱ្យមន្ត្រីឥណទានប្រគល់ឯកសារឱ្យបានមុនអតិថិជនមកដល់ការិយាល័យ ព្រោះកុំឱ្យអតិថិជនរង់ចាំយូរពេក។

# ឯកសារយោង (References)


១. Blogger. (2016, May 5,). *និយមន័យឥណទាន*. Retrieved June, 10 2025, from https://ocsrp.blogspot.com/2016/05/blog-post_78.html?m=1

២. Wikipedia. (2025, March 25). *Credit*. Retrieved June, 10 2025, from https://en.wikipedia.org/wiki/Credit

៣. CFI Education Inc. CFI Team. *Types of Credit*. Retrieved June, 10 2025, from https://corporatefinanceinstitute.com/resources/commercial-lending/types-of-credit/

៤. កាក់សេន. (2020, June 19). *និយមន័យនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*. Retrieved June, 12 2025, from https://www.facebook.com/kakcentkh/

៥. AMS. Mr. Heng Sovann. (2021, September 29). *យល់ដឹងពីប្រវត្តិសង្ខេបនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា*. Retrieved June, 1 2025, from https://economy.ams.com.kh/42867

៦. khemsarith.wordpress. khemsarith. (2016, October 12). *តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*. Retrieved June, 15 2025, from https://khemsarith.wordpress.com/2016/10/12/

៧. Lareine Media. វល័ក្ខ. (2018, June 13). *គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានតួនាទីអ្វីខ្លះនៅក្នុងសេដ្ឋកិច្ចសង្គម និងការរស់នៅរបស់ពលរដ្ឋ?* Retrieved June, 15 2025, from https://lareine.com.kh/news/economy/24722/

៨. CFI Education Inc. Tim Vipond, FMVA. (2019). *Finance Definition*. Retrieved June, 15 2025, from https://corporatefinanceinstitute.com/resources/wealth-management/what-is-finance-definition/

៩.CamboFinance. (2021, February14). *អ្វីទៅជាហិរញ្ញវត្ថុ?* Retrieved June, 18 2025, from https://www.facebook.com/CamboFinance/posts/pfbid024QsBh3Dv6Y7JSHuDKdwoMJvZWcbrL9iqoyZjs5w671CzSPnugVHdSrpW6uGQqa8Jl/

១០. Wikipedia. (2025, April 19). *Finance*. Retrieved June, 18 2025, from https://en.wikipedia.org/wiki/Finance

១១. អាត គីមម៉ី,សឿង ស្រីមុំ, ង៉ែត សេងហួយ,អឹម ដានីត,ប៉ាក ស្រីនាត.(២០២៣). *ដំណើរការឥណទានរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២០ ជំនាញគណនេយ្យ. ទំព័រទី៨. ៣៥ទំព័រ

១២. *លោក ផាន់ ម៉ាឡា | Mr. Phann Mala នាយកសាខា អេ អឹម ខេ៖ អគារលេខ ២៨៥ មហាវិថីយោធពលខេមរភូមិន្ទ (២៧១) សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ (បន្ថែមជំពូកទី៣ និង ផ្តល់ឱ្យនូវជំពូកទី៤MAY-03-2025 & MAY-25-2025)*

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
ល.រៈ [illegible]/វជ

**នាយកវិទ្យាស្ថាន វ៉ាន់ដា**
**គោរពជូន**
**លោក ឆាន់ ម៉ានិា**
**នាយកសាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី**

**កម្មវត្ថុៈ** សំណើសុំការអនុញ្ញាតឱ្យនិស្សិតចំនួន ៥នាក់ ចុះកម្មសិក្សាស្រាវជ្រាវនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី លើប្រធានបទ «ដំណើរការនៃការផ្តល់ឥណទានរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី»។

សេចក្តីដូចចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន លោកនាយកសាខា មេត្តាជ្រាបថា និស្សិតដែលបានទទួលការបណ្តុះបណ្តាល នៅវិទ្យាស្ថាន វ៉ាន់ដា មានទិសដៅចាំបាច់ក្នុងការបង្កើនចំណេះដឹងរបស់ខ្លួន ដោយផ្សារភ្ជាប់រវាងទ្រឹស្តីទៅនឹងការអនុវត្តន៍ជាក់ស្តែង ព្រមទាំងបទពិសោធន៍ជាមូលដ្ឋានគ្រឹះសម្រាប់ការសរសេរនិក្ខេបបទបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២ ក្នុងឆ្នាំសិក្សា ២០២៤-២០២៥ នេះ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោកនាយកសាខា មេត្តាពិនិត្យ និងអនុញ្ញាតឱ្យនិស្សិតវិទ្យាស្ថានយើងខ្ញុំ បានសិក្សាស្វែងយល់ពីប្រធានបទខាងលើដោយក្តីអនុគ្រោះ។

សូមលោកនាយកសាខា ទទួលនូវការគោរពរាប់អានអំពីខ្ញុំបាទ។

ថ្ងៃ[illegible]ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី[illegible]ខែមីនា ឆ្នាំ២០២៥
**នាយកវិទ្យាស្ថាន**

បណ្ឌិត **ហេង_វ៉ាន់ដា**

**សូមជូនភ្ជាប់មកជាមួយនូវៈ**
-បញ្ជីឈ្មោះនិស្សិតចុះកម្មសិក្សា ១ច្បាប់

អាសយដ្ឋានៈ អគារលេខ ២១៦-២១៨ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
Address: Nº216-218, Mao Tse Toung Blvd., Sangkat Tumnub Toek, Khan Boeng Keng Korng, Phnom Penh.
ទូរស័ព្ទៈ ០២៣ ២១៣ ៥៦៣ ទូរស័ព្ទដៃៈ ០៦៩ ៥៧០ ៥៦១ ហ្វេសប៊ុកៈ VANDA Institute អ៊ីមែលៈ vanda@camnet.com.kh វេបសាយៈwww.vanda.edu.kh
Tel: 023 213 563, H/P:069 570 561, Facebook: VANDA Institute, E-mail: vanda@camnet.com.kh. Website: www.vanda.edu.kh

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
ល.រៈ [illegible]/វជ

**បញ្ជីឈ្មោះនិស្សិតដែលស្នើសុំចុះកម្មសិក្សា**

| ល.រ | អត្តលេខ | គោត្តនាម និងនាម | ភេទ | លេខទូរស័ព្ទ |
|---|---|---|---|---|
| ១ | B22/220 | សុខ សាមើ | ប្រុស | ០៧៧ ៤២៤ ១១០ |
| ២ | B22/219 | ម៉ៅ មិថុនា | ស្រី | ០៩៦ ៤៥៧ ៦៤៦ ៦ |
| ៣ | B22/205 | ភា កញ្ញា | ស្រី | ០៩៦ ២៦២ ២៩៧ ២ |
| ៤ | B22/214 | សុខ ស្រីលីស | ស្រី | ០១០ ៣៧៣ ៨៥៧ |
| ៥ | B22/298 | រុំ ដាលីស | ស្រី | ០៧០ ៧៣៣ ៧១៨ |

សរុបបញ្ជីឈ្មោះត្រឹមចំនួន ៥នាក់ (ប្រាំនាក់)។

ថ្ងៃ[illegible]ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី[illegible]ខែមីនា ឆ្នាំ២០២៥
**នាយកវិទ្យាស្ថាន**

បណ្ឌិត **ហេង_វ៉ាន់ដា**

អាសយដ្ឋានៈ អគារលេខ ២១៦-២១៨ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
Address: Nº216-218, Mao Tse Toung Blvd., Sangkat Tumnub Toek, Khan Boeng Keng Korng, Phnom Penh.
ទូរស័ព្ទៈ ០២៣ ២១៣ ៥៦៣ ទូរស័ព្ទដៃៈ ០៦៩ ៥៧០ ៥៦១ ហ្វេសប៊ុកៈ VANDA Institute អ៊ីមែលៈ vanda@camnet.com.kh វេបសាយៈwww.vanda.edu.kh
Tel: 023 213 563, H/P:069 570 561, Facebook: VANDA Institute, E-mail: vanda@camnet.com.kh. Website: www.vanda.edu.kh

- **ទីតាំងតូមិសាស្រ្តរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខា** (២៧១)




